CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៤ ថ្ងៃទី០១-៣១ ខែតុលា ឆ្នាំ២០១១ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៥០

មាតិកា



យុវជនត្រូវតែអនុវត្តសិទ្ធិ... ទំព័រ ៥



ទឹកជំនន់ប៉ះពាល់ព្រះសហគមន៍ ទំព័រ ១៤



អត្ថន័យបុណ្យភ្ជុំក្នុងព្រះសហគមន៍ ទំព័រ ១៧

# ពលរដ្ឋសូមឱ្យពង្រឹងគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព បន្ថែមទៀត



គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គឺជាយុទ្ធសាស្ត្រថ្មីរបស់រាជរដ្ឋាភិបាល ក្នុងការរក្សា និងស្វែងរកសេចក្តីសុខសាន្តដល់ប្រជាពលរដ្ឋ តាមរយៈការបង្កើងប្រព័ន្ធសុវត្ថិភាពមួយសម្រាប់ភូមិ-ឃុំ បន្ថែមពីលើកងកម្លាំងប្រដាប់អាវុធដើម្បីចូលរួមទប់ស្កាត់នូវភាពអសកម្ម និងរាល់បទល្មើសផ្សេងៗ។ តើគោលនយោបាយនេះមានដំណើរការយ៉ាងដូចម្តេច? ហើយប្រជាពលរដ្ឋយល់ឃើញយ៉ាងណា? ទំព័រទី១០-១១

កម្មវិធីវិទ្យុ

## អេម៉ានូអែល

សំឡេងពីព្រះសហគមន៍កាតូលិក!

ភ្នំពេញ : **FM 102.5 Mhz** ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : **FM 91.0 Mhz** ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប: **FM 102.5 Mhz** ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : **FM 88.5 Mhz** ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : **FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : **FM 107.5 Mhz** ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : **FM 93.25 Mhz** ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

# រូបភាពប្រចាំខែ



Photos : S. Philong

គិតមកដល់ថ្ងៃទី១០ ខែតុលា ទឹកជំនន់បានជន់លិចនៅ ១៧ ខេត្ត-ក្រុង
នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងធ្វើឲ្យមនុស្ស ២០៧នាក់បានស្លាប់។



Photo : V. Sambath

នៅពេលទឹកជំនន់ អគ្គីសនីគួរតែបង្ការដោយការយកចិត្តទុក
ដាក់ខ្ពស់បំផុតពីព្រោះវាអាចបង្កឲ្យមានការឆក់រាលដាល។



នៅពេលទឹកជន់លិចកុមារ ប្រឈមមុខខ្ពស់បំផុតនឹងការលង់ទឹក និងការ
ប៉ះពាល់សុខភាព។ ដូច្នេះសាច់ញាតិចាស់ទុំគួរប្រុងប្រយ័ត្នបំផុតចំពោះពួកគេ។



ពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរកាលពីថ្ងៃទី២៦-២៨ តុលា ប្រជាជនខ្មែរយកចង្ហាន់
ទៅតាមវត្តអារាមនានា នៅទូទាំងប្រទេស ទោះបីមានការរំខានពីទឹកជំនន់ក៏ដោយ។



ការឈប់ចតដោយមានសណ្តាប់ធ្នាប់នៅមុខភ្លើងស្តុប បង្ហាញពីអាកប្បកិរិយា
ថ្លៃថ្នូររបស់ប្រជាពលរដ្ឋដែលមានវប្បធម៌ និងសេចក្តីថ្លៃថ្នូរ និងគោរពច្បាប់។

# វិចារណកថា

## ទាំងអស់គ្នារួមគ្នាដើម្បីសេចក្តីសុខសាន្តនៅមូលដ្ឋាន



លោកលី សុវណ្ណា ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

សម្រាប់គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ចំណុចទីមួយ គឺធ្វើឱ្យមូលដ្ឋានគ្មានសកម្មភាពលួចឆក់ និងការប្លន់គ្រប់ប្រភេទ។ ចំណុចទី២ គឺជំរុញឱ្យមូលដ្ឋានគ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់។ ចំណុចទី៣ គឺធ្វើឱ្យមូលដ្ឋាន គ្មានអំពើអនាចារ ការជួញដូរស្ត្រី កុមារ និងអំពើហិង្សាក្នុងគ្រួសារ។ ចំណុចទី៤ គឺបង្ក លក្ខណៈលុបបំបាត់ចោលនូវក្មេងទំនើងនៅក្នុងមូលដ្ឋាន។ ហើយចំណុចចុងក្រោយនោះ គឺធ្វើឱ្យមូលដ្ឋានគ្មាន ការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ គ្មានការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសផ្សេងៗ។

ទាំងនេះពិតជាគ្រឹះនៃការធានានូវសន្តិសុខ សុវត្ថិភាពនៅក្នុងមូលដ្ឋាន និងឱ្យប្រជាជនមានភាពកក់ក្តៅ។ ដូច្នេះដើម្បីសម្រេចធ្វើឱ្យបាននូវគោលនយោបាយនេះ អាជ្ញាធរបានបង្កើតជាប្រជាជនការពារភូមិ-ឃុំនីមួយៗ។

តើនេះពិតជាជួយឱ្យសម្រេចគោលនយោបាយទាំងនោះមែនឬយ៉ាងណា ? តើយើងបានគិតថា នេះគឺជាកតាព្វកិច្ចសម្រាប់តែអាជ្ញាធរប៉ុណ្ណោះឬ? តាមពិត គោលនយោបាយនេះត្រូវការចូលរួមពីប្រជាពលរដ្ឋយ៉ាងសកម្មនៅក្នុងមូលដ្ឋានទាំងមូល។ ប្រជាពលរដ្ឋត្រូវការយល់ដឹងគោលនយោបាយខាងលើនេះឱ្យបានទូលំទូលាយ។ យុវជន យុវនារីក៏ត្រូវតែទទួលបាននូវការលើក ទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មនៅក្នុងមូលដ្ឋាននីមួយៗ។ ប្រជាពលរដ្ឋតែងបន្ទោសទៅលើសមត្ថកិច្ច ឬអាជ្ញាធរ ពេលមានភាពពុំប្រក្រតីនៅក្នុងមូលដ្ឋានរបស់ខ្លួន ឬធ្វើការបន្ទោសភាពយឺតយ៉ាវរបស់សមត្ថកិច្ចក្នុងការចាត់វិធានការជាដើម។ ចំណែកអាជ្ញាធរបន្ទោសលើការរាយការណ៍របស់ប្រជាជននិងមិនទាន់ពេលវេលាក៏មានដែរ។ បើដូច្នេះ តើយើងអាចអនុវត្តគោលនយោបាយនេះ បានដោយរលូនដែរ ឬយ៉ាងណា?

យើងអាចមានវិធានមួយដែរ គឺប្រជាពលរដ្ឋត្រូវមានការសហការគ្នានៅក្នុងសហគមន៍ និងជាមួយអាជ្ញាធរមានសមត្ថកិច្ចឱ្យកាន់តែជិតស្និទ្ធ និងប្រសើរឡើង ដើម្បីឱ្យមានទំនុកចិត្តចំពោះគ្នាទៅវិញទៅមកក្នុងការដោះស្រាយបញ្ហារួម។

---

### សេចក្តីជូនដំណឹង

កម្មវិធីវិទ្យុ ខ្ញុំត្រូវការអ្នក នៃការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍រៀបចំការប្រឡង និពន្ធអត្ថបទល្ខោននិយាយ និងអត្ថបទចម្រៀង។

លក្ខខណ្ឌ : ១- បេក្ខជន-នារីត្រូវមានអាយុ ១៥ឆ្នាំឡើង។ ២-អត្ថបទល្ខោននិយាយ និងចម្រៀងត្រូវមានខ្លឹមសារអប់រំយុវវ័យលើបញ្ហា ជាក់ស្តែងក្នុងសង្គមដូចជា ការសិក្សា ការកំសាន្ត ស្នេហា...។ ៣-អត្ថបទល្ខោននិយាយនិពន្ធពី១២ ទៅ១០០ទំព័រ។ ៤-អត្ថបទចម្រៀង ត្រូវមានទំនុកច្រៀងភ្ជាប់។

ព័តមានបន្ថែម : ០៩២ ៧៤០ ០០២/០៩៧ ៩៣០ ៩៨៩០ ឬអ៊ីមែល vccradio@gmail.com **អរគុណ!**

### ពន្លកថ្មី

**ជាកម្មវិធីវិទ្យុថ្មីមួយរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក។ កម្មវិធីនេះផ្តោតលើពលកម្មកុមារ និងបង្ការការកេងប្រវ័ញ្ច លើកុមារ ដែលសហការជាមួយវិទ្យុសម្លេងប្រជាធិបតេយ្យ VOD។ ផ្សាយនៅរាល់ ថ្ងៃច័ន្ទ ម៉ោង ៤-៥ រសៀល ផ្សាយនៅវិទ្យុ FM 106.5 MHz ។**

### កម្មវិធីវិទ្យុ "ខ្ញុំត្រូវការអ្នក"

"ខ្ញុំត្រូវការអ្នក" ខែតុលា (FM 99.5 Mhz ច័ន្ទ,អង្គារ ម៉ោង ១០-១១ព្រឹក)

ថ្ងៃទី០៣ តុលា : ម្តាយខ្ញុំ។ ថ្ងៃទី០៤ តុលា : ឪពុកខ្ញុំ។ ថ្ងៃទី១០ តុលា : យុវវ័យ និងការបរិច្ចាគឈាម។ ថ្ងៃទី១១ តុលា : ស្ត្រី និងការងារស្ម័គ្រចិត្ត។ ថ្ងៃទី១៧ តុលា : ការជ្រើសរើសបុគ្គលិក។ ថ្ងៃទី១៨ តុលា : មុខងារព័ត៌មានវិទ្យា។ ថ្ងៃទី២៤ តុលា : មុខងារទីផ្សារ។ ថ្ងៃទី២៥ តុលា : យុវវ័យ និងភាពជោគជ័យក្នុងអាជីវកម្ម។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះ នឹងមានការចូលរួមបកស្រាយពីវាគ្មិនដែលមាន បទពិសោធន៍ និងជំនាញច្បាស់លាស់។

**សូមកុំភ្លេចតាមដាន!**

### កម្មវិធីវិទ្យុ អេម៉ានូអែល

អ្នកចូលរួមកម្មវិធីអេម៉ានូអែល "សម្លេងពីព្រះសហគមន៍កាតូលិក" ខែតុលា

-ថ្ងៃអាទិត្យទី២ ខែតុលា អាទិត្យ ទី២៧ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យ ស្រ៊ីប្រាម៉ុង វីរជ័យ មកពីព្រះសហគមន៍ ខេត្តព្រះសីហនុ។

-ថ្ងៃអាទិត្យទី៩ ខែតុលា អាទិត្យ ទី២៨ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យអ៊ុន សុន មកពីព្រះសហគមន៍កំពត។

-ថ្ងៃអាទិត្យទី១៦ ខែតុលា អាទិត្យ ទី២៩ ក្នុងរដូវធម្មតា : លោកបូជាចារ្យប៉្រុយណូ កូសម៉ី អ្នកទទួលខុសត្រូវព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) រាជធានីភ្នំពេញ។

-ថ្ងៃអាទិត្យទី២៣ ខែតុលា អាទិត្យ ទី៣០ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យលូកា មកពីព្រះសហគមន៍កាតូលិកតំបន់កំពត។

-ថ្ងៃអាទិត្យទី៣០ ខែតុលា អាទិត្យ ទី៣១ ក្នុងរដូវធម្មតា : ចូលរួមដោយលោកបូជាចារ្យហ្វ្រង់កូ ឡេញ៉ានី មកពីព្រះសហគមន៍ខេត្តកំពង់ឆ្នាំង។

# សេដ្ឋកិច្ច

## ផលិតផលវិស័យព័ត៌មានវិទ្យាកម្ពុជាកំពុងបានការទទួលស្គាល់

**ខាន់ ភីរម្យ**


Photo : S. Philong

"ការវិនិយោគលើវិស័យព័ត៌មានវិទ្យានៅកម្ពុជាកំពុងតែទទួលបានជោគជ័យនិងដណ្ដើមបានទីផ្សារនៅអន្តរជាតិ"។ នេះបើតាមការអះអាងពីប្រធានសមាគមបច្ចេកវិទ្យាទូរគមនាគមន៍មួយ។

លោកកេន ចាន់ថន បានមានប្រសាសន៍ថា មកដល់ពេលនេះ កម្ពុជាមានក្រុមហ៊ុនមួយចំនួនកំពុងអភិវឌ្ឍកម្មវិធីកុំព្យូទ័រសម្រាប់បម្រើដល់ក្រុមហ៊ុនធំៗនៅក្នុងប្រទេសនៅអឺរ៉ុប និងអាមេរិក។ លោកបញ្ជាក់ថា ក្រុមហ៊ុន ទាំងនោះកំពុងអភិវឌ្ឍសូវវែរ ហើយលក់ទៅកាន់ទីផ្សារនៅបរទេសតាមរយៈការធ្វើការម៉ៅការបន្ត។

លោកកេន ចាន់ថន បានបន្តឱ្យដឹងថា មកដល់ពេលនេះ មានក្រុមហ៊ុនដែលកំពុងអភិវឌ្ឍនូវកម្មវិធីបែបនេះប្រមាណជា ១០ក្រុមហ៊ុន ហើយបណ្ដាក្រុមហ៊ុនទាំងនេះបានផ្ដល់ការងារធ្វើ ដល់បុគ្គលិកជាពលរដ្ឋខ្មែរប្រមាណជា ១០០០នាក់។

លោកកេន ចាន់ថន បញ្ជាក់ថា ឥឡូវនេះស្នាដៃប្រជាពលរដ្ឋខ្មែរនៅលើផ្នែកនេះមិនមែនធម្មតាទេ ហើយស្នាដៃរបស់ពួកគាត់ ចាប់ផ្ដើមទទួលបាននូវការទទួលស្គាល់ពីទីផ្សារបរទេសជាបណ្ដើរៗ។

លោកកេន ចាន់ថន ឱ្យដឹងថា ពីមុននៅអឺរ៉ុប គេច្រើនឱ្យតម្លៃស្នាដៃបែបនេះទៅដល់បណ្ដាប្រទេសមួយចំនួន ដូចជាឥណ្ឌា និងចិនជាដើម។ ប៉ុន្តែឥឡូវនេះ គេបានចាប់ផ្ដើមងាកមករកទីផ្សារ នៅអាស៊ីជាពិសេសគឺអាស៊ីអាគ្នេយ៍ដូចជាកម្ពុជា និងវៀតណាមជា ដោយសារតែតម្លៃពលកម្មនៅថោក។

នៅចន្លោះពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ នៅក្នុងចំណោមនិស្សិតដែលរៀនចប់បរិញ្ញាបត្រផ្សេងៗដែលមាននៅក្នុងបណ្ដាសកលវិទ្យាល័យនានានោះ និស្សិតដែលបញ្ចប់ការសិក្សា លើផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ មានចំនួន ៧.៩%។

លោកកេនចាន់ថន បញ្ជាក់ថា: "ប្រសិនកម្ពុជារៀបចំគោលនយោបាយត្រឹមត្រូវលើផ្នែកនេះ វាអាចជាប្រភពចំណូលមួយដែរ សម្រាប់បន្ថែមទៅលើប្រាក់ចំណូលជាតិ និងអាចផ្ដល់ការងារជាច្រើនដល់យុវនិស្សិតក្មេងៗសម័យថែមទៀតផងដែរ"។

លោកកេន ចាន់ថន ក៏បន្ថែមថា វិស័យបច្ចេកវិទ្យាព័ត៌មាន នៅប្រទេសកម្ពុជា បច្ចុប្បន្ននេះ រីកចម្រើនខ្លាំងណាស់ ជាពិសេស នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

### ៧ខែដើមឆ្នាំ វិស័យកសិកម្ម សេវាកម្ម និងទូរគមនាគមន៍ ទទួលគម្រោងវិនិយោគតម្លៃ ៤៦០លានដុល្លារ

យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានឱ្យដឹងថា ទឹកប្រាក់ដែលគេសន្យាថា នឹងវិនិយោគនៅកម្ពុជា ក្នុងរយៈពេល ៧ខែដើមឆ្នាំ គឺមានតម្លៃសរុបប្រមាណជា ៥,៥ពាន់លានដុល្លារ នៅក្នុងនោះគម្រោងវិនិយោគលើវិស័យកសិកម្ម ផ្នែកសេវាកម្ម និងទូរគមនាគមន៍មានតម្លៃសរុប ប្រមាណជា ៤៦០លានដុល្លារ ដោយឡែកគម្រោង វិនិយោគលើវិស័យឧស្សាហកម្ម មានទឹកប្រាក់រហូតដល់ទៅ ២,៦ពាន់លានដុល្លារ និងវិស័យទេសចរណ៍មានតម្លៃប្រមាណជា ២,៤៤ពាន់លានដុល្លារ។

អ្នកវិនិយោគទុន ដែលសន្យាថា នឹងវិនិយោគធំជាងគេនៅកម្ពុជា គឺអង់គ្លេស ចិន និងអ្នកវិនិយោគទុននៅក្នុងស្រុក។

# សុខភាព

## អ្នករស់នៅតំបន់ព្រៃភ្នំត្រូវប្រុងប្រយ័ត្ននឹងជំងឺគ្រុនចាញ់

**ជាត សំភី**


Photo : S. Philong

"ជំងឺគ្រុនចាញ់បណ្ដាលមកពីមូសដែកគោញីខាំ"។ នេះបើយោងតាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិតឈៀវ គន្ធារី ដែលធ្វើការនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

លោកបណ្ឌិតឈៀវ គន្ធារី មានប្រសាសន៍ឱ្យដឹងទៀតដែរថា ជំងឺគ្រុនចាញ់នេះច្រើនតែកើតនៅរដូវភ្លៀង។ ប៉ុន្តែនៅតំបន់ព្រៃភ្នំប្រជាជនប្រឈមមុខនឹងជំងឺគ្រុនចាញ់គ្រប់រដូវដោយសារមានដើមឈើដុះស៊ុបទ្រុប។ ដូច្នេះនៅប្រទេសកម្ពុជា តំបន់ភ្នំនិងតំបន់ខ្ពង់រាប ដូចជាខេត្តកំពង់ស្ពឺ ពោធិ៍សាត់ បាត់ដំបង សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី ឬក៏មណ្ឌលគិរី... ប្រជាជនមានអត្រាប្រឈមនឹងជំងឺគ្រុនចាញ់នេះខ្ពស់បំផុត។ ជំងឺគ្រុនចាញ់នេះ អាចកើត លើមនុស្សគ្រប់វ័យ ដោយមិនប្រកាន់ថា វ័យណានោះឡើយ។

រោគសញ្ញារបស់ជំងឺគ្រុនចាញ់ មានដូចជា រងាញាក់ ក្ដៅខ្លួន រួចហើយបែកញើស...។ ហើយរោគសញ្ញានេះកើតឡើងរាល់ថ្ងៃ ឬរំលងមួយថ្ងៃម្ដង។

លោកវេជ្ជបណ្ឌិតឈៀវគន្ធារី សង្កត់ធ្ងន់ថា: "បើបើមានរោគសញ្ញានេះ ត្រូវបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ដើម្បីគ្រូពេទ្យជំនាញ ពិនិត្យធ្វើរោគវិនិច្ឆ័យ រួចហើយធ្វើការព្យាបាលជាបន្ទាន់។ បើបណ្ដោយ អ្នកជំងឺអាចស្លាប់បាន"។

លោកវេជ្ជបណ្ឌិតឈៀវ គន្ធារី គូសបញ្ជាក់ថា: "ប្រជាជនដែលរស់នៅតំបន់ដែលប្រឈមនឹងជំងឺគ្រុនចាញ់ ត្រូវយកចិត្តទុកដាក់ខ្ពស់បំផុត ដើម្បីធ្វើបង្ការជំងឺគ្រុនចាញ់នេះ"។

លោកវេជ្ជបណ្ឌិតបន្តថា គេអាចបង្ការខ្លួន បានដោយការពារកុំឱ្យមូសដែកគោញីខាំ ដូចជាគេត្រូវពាក់ខោអាវវែងៗជិតៗ រកថ្នាំលាបដៃជើងការពារមូស គេងក្នុងមុងជ្រលក់ថ្នាំ ជាដរាប ជាពិសេស គឺត្រូវប្រើមុងជ្រលក់ថ្នាំនៅរាល់ពេលដើរព្រៃ។

# យុវវ័យ

# យុវជនត្រូវតែអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមបោះឆ្នោត

**ខាន់ ភីរម្យ**

អ្នកជំនាញខាងធ្វើការតស៊ូមតិ ដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងអ្នកជំនាញដែលធ្វើកិច្ចការច្រើនជាមួយយុវជនបានជំរុញឱ្យយុវជនទាំងអស់ ដែលគ្រប់អាយុបោះឆ្នោត ឱ្យទៅចូលរួមការបោះឆ្នោត ពីព្រោះយុវជនគឺជាសសរទ្រូង និងជាម្ចាស់លើជោគវាសនារបស់ប្រទេសជាតិ ។

លោកគល់ បញ្ញា ជានាយកប្រតិបត្តិនៃអង្គការខុមហ្វ្រែល បាននិយាយឱ្យដឹងថា សព្វថ្ងៃនេះ យុវ-ជនដែលគ្រប់អាយុ ហើយអាចនឹងចូលរួមការបោះឆ្នោតនោះ មានរហូតដល់ទៅជាងមួយលាននាក់ ។ លោកគល់ បញ្ញា ក៏បានឱ្យដឹងថា យុវជនទាំងអស់ដែល ចង់បង្ហាញអំពីទំនួលខុសត្រូវសង្គម របស់ខ្លួនគួរតែត្រូវទៅចុះ ឈ្មោះបោះឆ្នោត ហើយចូលរួមការបោះឆ្នោតទាំងអស់គ្នា ។ លោកគល់ បញ្ញា បានប្រាប់ឱ្យដឹងថា យុវជន និងយុវនារី ជាង មួយលាននាក់ ដែលគ្រប់អាយុបោះឆ្នោត គួរតែទៅចូលរួមការបោះឆ្នោត ពីព្រោះការបោះឆ្នោត គឺជាពេលដ៏សំខាន់ ដែលយើងជាពលរដ្ឋ អាចសម្តែងឡើងនូវសិទ្ធិរបស់ពួកយើងម្នាក់ៗ នៅក្នុងនាមយើងធ្វើជាម្ចាស់សន្លឹកឆ្នោត ។

លោកព្រាប កុល ឯកអគ្គរាជទូតសន្តិភាពមួយរូបនៃសហព័ន្ធសន្តិភាពសកលលោកក៏បានប្រាប់ឱ្យដឹងដែរថា ការបោះឆ្នោតគឺមានសារៈសំខាន់ណាស់សម្រាប់ពលរដ្ឋម្នាក់ៗ ពីព្រោះ នេះគឺជាពេលវេលាដែលបង្ហាញថា យុវជនគ្រប់រូបក៏ជាម្ចាស់លើជោគវាសនារបស់ប្រទេសជាតិដូចប្រជាពលរដ្ឋឯទៀតៗដែរ ។ លោកព្រាប កុល បញ្ជាក់ថា : "ទោះបីជាយើងនៅក្មេង តែយើងក៏មានការយល់ដឹងនិងមានការអប់រំ ហើយយើងម្នាក់ៗ ដែលជាយុវជនមានសិទ្ធិគ្រប់គ្រាន់ដើម្បីធ្វើការសម្តែងឆន្ទៈរបស់យើងក្នុងការបោះឆ្នោត ដែលនេះជាពេលវេលាដ៏សំខាន់សម្រាប់ជ្រើសរើសអ្នកដឹកនាំប្រទេសផងដែរ" ។

តាមប្រសាសន៍របស់លោកគល់ បញ្ញា ក៏បានឱ្យដឹងថា កម្ពុជាគ្រោងនឹងរៀបចំការបោះឆ្នោតចំនួនពីរសំខាន់ៗ គឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ នៅក្នុងឆ្នាំ២០១២ខាងមុខនេះ និងការបោះឆ្នោតជាតិដែលគ្រោងនឹងរៀបចំឡើងនៅក្នុងអំឡុងឆ្នាំ២០១៣ខាងមុខ ។

យុវនារីវង្ស សុនាថ កម្មការិនីរោងចក្រកាត់ដេរវ័យ១៩ឆ្នាំ មួយរូប និយាយឱ្យដឹងថា រូបកញ្ញាបានត្រៀមខ្លួនរួចហើយ សម្រាប់ចូលរួមការបោះឆ្នោតជា លើកទីមួយរបស់នាង ។ សុនាថ បានឱ្យដឹងថា : "ខ្ញុំចុះឈ្មោះរួចហើយ ចាំតែថ្ងៃបោះឆ្នោតមកដល់ ខ្ញុំនឹងទៅបោះឆ្នោតនឹងគេហើយ" ។ សុនាថ បានចុះឈ្មោះនៅក្នុងស្រុកកំណើតរបស់នាងដែលមានទីលំនៅនៅស្រុកបាទី ខេត្តតាកែវ ជាមួយនិងមិត្តភក្តិ ។ សុនាថបានឱ្យដឹងថា នៅក្នុងចំណោមកម្មករនិងកម្មការិនី ដែលចូលបម្រើការងាររោងចក្រកាត់ដេរនៅភ្នំពេញជាមួយគ្នាភាគច្រើន ពួកគេបានចុះឈ្មោះរួចរាល់ហើយ ប៉ុន្តែក៏នៅមានអ្នកខ្លះនៅមិនទាន់បានចុះឈ្មោះផងដែរ ។ សុនាថបញ្ជាក់ថា : "ខ្ញុំទៅចុះឈ្មោះ ដោយសារតែម៉ែគាត់ទូរស័ព្ទពីផ្ទះឱ្យទៅចុះឈ្មោះ ហើយខ្ញុំក៏ទៅផ្ទះជាមួយនិងមិត្តភក្តិមកពីភូមិជាមួយគ្នាចុះទៅ" ។

ចំណែកយុវជនមួយរូបទៀតដែលកំពុងសិក្សាជំនាញវិទ្យាសាស្ត្រកុំព្យូទ័រ នៅវិទ្យាស្ថានមួយ នៅរាជធានីភ្នំពេញបានឱ្យដឹងដែរថា រូបគេនៅមិនទាន់បានទៅចុះឈ្មោះបោះឆ្នោតនៅឡើយទេ បើទោះបីជានៅពេលនេះ រូបគេមានអាយុ២០ឆ្នាំហើយ ក៏ដោយ ។ យុវជនរូបនោះក៏បានបញ្ជាក់ទៀតថា: "ខ្ញុំឃើញព័ត៌មាន នៅតាមទូរទស្សន៍ឱ្យទៅចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត តែខ្ញុំមិនដឹងចុះនៅឯណា ក៏ចេះតែហឺៗទៅ ដែលរហូតមកដល់ពេលនេះខ្ញុំមិនទាន់ចុះផង" ។ យុវជនរូបនោះប្រាប់ឱ្យដឹងទៀតថា រូបគេនៅមិនទាន់បានទៅចូលរួមការបោះឆ្នោតនៅឡើយទេ ។ តែគេចេះតែរវល់ ហើយមិនដឹងជាទៅចុះឈ្មោះទៅទីណា និងបោះឆ្នោតរបៀបម៉េច ក៏ដូចជាខ្ជិលទៅតែម្តងទៅ ។



Photo : Philong

# ទីផ្សារដំឡូងមីភាគច្រើនពឹងផ្អែកលើប្រទេសជិតខាង

**ជាត សំភី**

បើតាមអ្នកជំនួញដំឡូងមីមួយរូប នៅឯស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា មកដល់ខែនេះ ដំឡូងមីស្រស់ក្នុងមួយគីឡូក្រាម មានតម្លៃប្រហែលចន្លោះ ២៥០-២៧០រៀល។ នេះគឺជាតម្លៃខ្ពស់ជាងឆ្នាំមុន បើគិតមកដល់ខែដូចគ្នា។

លោកយ៉ែម ហៀប អគ្គនាយករងនៃក្រុមហ៊ុនប្រមូលទិញ និងនាំចេញដំឡូងមី ខេអិលវ៉ាយ មានប្រសាសន៍ថា តម្លៃរបស់ដំឡូងមីគឺប្រែប្រួលឡើងខ្ពស់បំផុត នៅខែមករា ឬកុម្ភៈ និងតម្លៃទាបបំផុតគឺនៅខែឧសភា ឬមិថុនា។ កាលពីឆ្នាំមុនតម្លៃទាបបំផុត ១៥០រៀល និងតម្លៃខ្ពស់បំផុត គឺ៤៤០រៀល សម្រាប់ដំឡូងមីស្រស់ មួយគីឡូក្រាម។

ទោះជាយ៉ាងណា លោកយ៉ែម ហៀប បានគូសបញ្ជាក់ថា: "ដំឡូងមីលក់បានតម្លៃខ្ពស់ជាងមុន។ ប៉ុន្តែថ្លៃផលិតកម្មក៏ឡើងថ្លៃដែរ។ ឈ្នួលកម្មករដាំដំឡូងឡើងថ្លៃ ថ្លៃដឹកជញ្ជូន ហើយនិងប្រេងឥន្ធនៈសម្រាប់គ្រឿងចក្រភ្ជួររាស់ក៏ឡើងថ្លៃដែរ។ នេះជាហេតុធ្វើឱ្យយើងចំណេញមិនបានច្រើន"។

លោកយ៉ែម ហៀប និយាយថា ក្រុមហ៊ុនរបស់លោកមានផ្ទៃដីដាំដុះចំនួន៥០០ហិចតា ជាមួយនិងទិន្នផល ២៥តោនក្នុងមួយហិចតា។ ទិន្នផលនេះគឺនៅទាប បើប្រៀបធៀបនឹងប្រទេសជិតខាង ដែលគេធ្វើបានដល់ ៦០ទៅ ៧០តោន ក្នុងមួយហិចតា។

លោកយ៉ែម ហៀប មានប្រសាសន៍ថា ក្រៅពីដំឡូងដែលក្រុមហ៊ុនលោកផលិត លោកអាចទិញដំឡូងពីប្រជាជននៅស្រុកស្វាយចេកនោះ ដែលដាំដុះដំឡូងមីប្រមាណជាង ១ម៉ឺន ហិចតា។ ប៉ុន្តែនៅខេត្តក្នុងបន្ទាយមានជ័យ ទាំងមូល មានផ្ទៃដីដាំដុះដំឡូងប្រមាណជាង ១០ម៉ឺនហិចតា។

លោកយ៉ែម ហៀប បន្តថា ទីផ្សារសំខាន់ គឺនៅប្រទេសថៃ។ បើថៃបិទទីផ្សារ យើងនឹងមានការលំបាកណាស់។ បើយើងយកទៅលក់នៅប្រទេសវៀតណាម យើងនឹងខាតនូវថ្លៃដឹកជញ្ជូន។ លោកនិយាយថា: "ប៉ុន្តែពេលខ្លះ ប្រទេសវៀតណាម គេខ្វះដំឡូងមី ឈ្មួញគេមកទិញយកដែរ។ខាងភ្នំពេញក៏ធ្លាប់មកយកដែរ"។

លោកយ៉ែម ហៀប បានអះអាងថា: "ដើម្បីឱ្យដំឡូងមីរបស់ប្រជាកសិករបានតម្លៃខ្ពស់ ទាល់តែមានអ្នកវិនិយោគមកសាងសង់ទីលានហាលដំឡូងមី ឬរោងចក្រកែច្នៃផ្សេងៗ"។ លោកយ៉ែម ហៀប ក៏បញ្ជាក់ថា ដំឡូងមីស្ងួត លក់បានថ្លៃ និងរក្សាទុកបានយូរជាង។ ដំឡូងមីស្រស់ យើងដកទុកតែពីបីថ្ងៃទៅមួយអាទិត្យ គឺរលួយខូចគុណភាពហើយ។

លោកសំណូមពរថា: "រដ្ឋាភិបាលគួរតែរៀបចំឱ្យមានឥណទានកម្ចី ឱ្យបានច្រើនសម្រាប់វិស័យដំឡូងមី។កន្លងមកយើងឃើញតែរដ្ឋផ្តល់ឥណទានដល់អ្នករោងម៉ាស៊ីនកិនស្រូវ និងវិស័យស្រូវ"។



Photo : S. Philong

បរិស្ថាន

## អ្នកណាជាអ្នកប្រឈមមុខខ្លាំងនឹងបម្រែបម្រួលអាកាសធាតុ ?

អ្នកជំនាញខាងស្រាវជ្រាវផ្នែកសង្គម និងបម្រែបម្រួលអាកាសធាតុមួយរូប បានអះអាងថា សព្វថ្ងៃនេះ នៅក្នុងចំណោមប្រជាពលរដ្ឋទាំង ១៤លាននាក់អ្នក ដែលប្រឈមមុខខ្លាំងនឹងបញ្ហាបម្រែបម្រួលអាកាសធាតុនោះ គឺកសិករ។



Photo : S. Philong

លោកតឹក វណ្ណារ៉ា អ្នកស្រាវជ្រាវរបស់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ បានមានប្រសាសន៍ថា បម្រែបម្រួលអាកាសធាតុ គឺផ្តល់ផលប៉ះពាល់ដល់មនុស្សគ្រប់ៗគ្នា ដែលរស់នៅលើផែនដីនេះ។ ដោយឡែក នៅប្រទេសកម្ពុជា អ្នកដែលប្រឈមមុខនឹងផលប៉ះពាល់ខ្លាំង គឺមានប្រមាណជា ៦៥%។

ពួកគាត់ភាគច្រើនគឺជាកសិករដែលមានមុខរបរជាអ្នកធ្វើកសិកម្ម ឬអ្នកចិញ្ចឹមសត្វខ្នាតតូចៗ ឬលក្ខណៈគ្រួសារ ពីព្រោះមុខរបរពួកគាត់ភាគច្រើនគឺពឹងអាស្រ័យលើធម្មជាតិ ១០០% ដូចជា ទឹក អាកាសធាតុ និងធនធានផ្សេងៗ។

លោកតឹក វណ្ណារ៉ា បានបន្តទៀតថា រូបភាពនៃឥទ្ធិពលពីការបម្រែបម្រួលអាកាសធាតុ ដែលធ្លាប់កើតមានឡើងនៅក្នុងប្រទេសកម្ពុជានោះ មានដូចជា ទឹកជំនន់ ភ្លៀងធ្លាក់ខ្លាំង គ្រោះរាំងស្ងួតអូសបន្លាយយូរ ធ្វើឱ្យទិន្នផលកសិកម្មថយចុះ និងព្យុះជាដើម ហើយមូលហេតុដែលកសិករតូចតាចងាយនឹងរងគ្រោះ គឺដោយសារតែពួកគាត់នៅមានសមត្ថភាពបន្សាំនឹងបញ្ហាទាំងនេះក្នុងកម្រិតទាបបំផុត។

លោកតឹក វណ្ណារ៉ា បានឱ្យដឹងថា ប្រទេសកម្ពុជាប្រឈមមុខបញ្ហាជាច្រើនដើម្បីដោះស្រាយបញ្ហាដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ ដូចជា កង្វះខាតមូលនិធិ និងធនធានមនុស្សជាដើម។

**ខាន់ ភីរម្យ**

# អ្នកក្រីក្របំផុតមានសង្ឃឹមដោយសារក្រុមបងស្រីមេត្តាករុណា



Photos : L. Samphors

**ជាត សំភី**

ជារៀងរាល់ខែ អ្នកជំងឺប្រមាណជាង ៨០នាក់ សុទ្ធសឹងជាអ្នកក្រីក្រខ្លាំងមកស្នាក់នៅ និងសម្រាកព្យាបាលជំងឺនៅភូមិស្ថានសន្តិភាពដែលដំណើរការដោយក្រុមបងស្រីមេត្តាករុណា នៅភូមិក្រាំងដូនទៃ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

បើតាមប្រសាសន៍របស់បងស្រីម៉ារី ប៉ែរទីណារ៉ែឌី អ្នកទទួលខុសត្រូវភូមិស្ថានសន្តិភាព បានឱ្យដឹងថា អ្នកដែលមកស្នាក់នៅទីនេះ មានជីវភាពក្រីក្រខ្លាំង និងគ្មានលទ្ធភាពព្យាបាលខ្លួន ។ ពួកគាត់គឺជាអ្នកជំងឺធ្ងន់ធ្ងរ ដូចជា ជំងឺអេដស៍ ជំងឺរបេង ជំងឺមហារីក ឬជំងឺគ្រុនពោះវៀន... ។ ពួកគាត់មកពីភូមិជុំវិញ និងគ្រប់តំបន់នៅទូទាំងប្រទេស ។

បងស្រីម៉ារី ប៉ែរទីណារ៉ែឌី បន្តថា : "នៅទីនេះ យើងផ្តល់ឱ្យអ្នកជំងឺនូវកន្លែងស្នាក់នៅ ម្ហូបអាហារ ការព្យាបាលបឋម ការនាំគាត់ទៅមន្ទីរពេទ្យ ថ្នាំព្យាបាល ការថែទាំ ការប្រឹក្សា និងបង្រៀនជំនាញខ្លះដូចជាដេរប៉ាក់ និងអក្សរដល់ក្មេងជាដើម" ។

បងស្រីម៉ារី បើរទីណារ៉ែឌី គូសបញ្ជាក់ដែរថា : "បេសកកម្មរបស់ក្រុមបងស្រីមេត្តាករុណា គឺនាំសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ឱ្យដល់ប្រជាជនដែលក្រីក្របំផុតដែលរងការឈឺចាប់ និងមានភាពឯកោតាមរយៈសកម្មភាពដែលធ្វើរាល់ថ្ងៃ" ។ បងស្រីបន្តថា : "យើងថែទាំមនុស្សជាច្រើនដោយមិនប្រកាន់សាសនា" ។ ដូច្នេះដោយការមើលឃើញនូវសកម្មភាពរបស់យើង ពួកគាត់នឹងបានស្គាល់ ព្រះជាម្ចាស់ និងសេចក្តីស្រឡាញ់របស់ព្រះអង្គ" ។

អ្នកស្រីណារី ឈ្មោះ(ប្រឌិត) មានស្រុកកំណើតនៅស្រុកល្វាឯម ខេត្តកណ្តាល និយាយថា អ្នកស្រីទទួលជំងឺអេដស៍ពីស្វាមី ។ ពីមុនអ្នកស្រីពិបាកចិត្តខ្លាំងមែនទែន ឯកោនិងអស់សង្ឃឹម ។ អ្នកស្រីណារីបន្តថា : "នៅពេលខ្ញុំមកដល់មណ្ឌលអារម្មណ៍របស់ខ្ញុំបានធូរស្បើយ និងរីករាយ ។ បងស្រីបានផ្តល់ឱ្យខ្ញុំតាំងពីអាហារបរិភោគ កន្លែង ស្នាក់នៅ ការថែទាំ ការលើកទឹកចិត្ត និងការណែនាំប្រឹក្សា... ដែលធ្វើឱ្យខ្ញុំមានសង្ឃឹមឡើងវិញ" ។

អ្នកស្រីសុខាឈ្មោះ(ប្រឌិត) មកពីស្រុកបារាយណ៍នៅខេត្តកំពង់ធំ មានជំងឺអេដស៍ មហារីក និងពិការភ្នែកទៀត ។ ប៉ុន្តែក្រុមបងស្រី នៅតែមើលថែអ្នកស្រី ។ អ្នកស្រីប្រាប់ថា : "ប្រសិនបើគ្មានជំនួយនេះទេ ។ ប្រាកដណាស់ ខ្ញុំនឹងស្លាប់ជាក់ជាមិនខាន" ។

យុវជនផន សុខុម មកពីស្រុកអង្គស្នួល ខេត្តកណ្តាល និយាយថា : "ខ្ញុំមានអារម្មណ៍សប្បាយរីករាយ ពីព្រោះក្រុមបងស្រីបានជួយខ្ញុំ ខណៈដែលខ្ញុំគ្មានលទ្ធភាពព្យាបាលខ្លួន" ។ លោកបន្តថា : "ខ្ញុំចងចាំអំពើល្អនេះដើម្បីទុកជួយអ្នកដទៃៗទៀត" ។

ភូមិស្ថានសន្តិភាព ត្រូវបានសាងសងឡើងនៅឆ្នាំ១៩៩៣ ក្រោយពេលដែលបងស្រីមេត្តាករុណាចូលមកដល់ប្រទេសកម្ពុជាដំបូងឆ្នាំ១៩៩០ដោយការទទួល និងស្វាគមន៍ ពីលោកអភិបាលអេមីលដេតម្ប ដើម្បីជួយប្រជាជនកម្ពុជាដែលក្រីក្រ ។

ក្រុមបងស្រីមេត្តាករុណា មានបីសហគមន៍ គឺទីមួយ សហគមន៍ចោមចៅភូមិស្ថាននៃសន្តិភាព ថែទាំ អ្នកជំងឺធ្ងន់ធ្ងរ និងស្ត្រីមានផ្ទុកមេរោគអេដស៍ ។ ទីពីរ សហគមន៍នៅផ្លូវមុនីវង្ស រាជធានីភ្នំពេញ ថែទាំកុមារក្រីក្រពិការ និងត្រូវបោះបង់ចោល ។ ទីបី សហគមន៍នៅខេត្តសៀមរាប ថែទាំកុមារ និងមានសាលាមត្តេយ្យ ។ ហើយក៏មានសហគមន៍បងប្រុសមេត្តាករុណានៅ សង្កាត់ចោមចៅ រាជធានីភ្នំពេញផងដែរ ដែលមើលថែទាំអ្នកជំងឺជាបុរស និងកុមារដែលមានផ្ទុកមេរោគអេដស៍ ។

ក្រុមបព្វជិតបព្វជិតា មេត្តាករុណា នៅប្រទេសកម្ពុជា មានបងស្រី ២១រូប និងបងប្រុស ៤រូប ។



បងស្រីម៉ារី ប៉ែរទីណារ៉ែឌី ប្រធានភូមិស្ថានសន្តិភាព ចុះសាកសួរ និងលើកទឹកចិត្តអ្នកជំងឺក្នុងមណ្ឌលបងស្រី



Photo : V. Sambath

## ខាន់ ភីរម្យ

### ទឹកជំនន់បង្ករការខូតខាត និង សម្លាប់ជីវិតមនុស្ស ២០៧ នាក់

គិតមកដល់ថ្ងៃទី១០ ខែតុលានេះ ទឹកជំនន់នៅកម្ពុជាបានសម្លាប់ជីវិតមនុស្ស ២០៧នាក់ ប៉ះពាល់ប្រជាជន ១៧០០០០គ្រួសារ ផ្ទៃដីបង្កបង្កើនផលរហូតដល់ទៅ ៣២ម៉ឺន ហិចតា និងខូចខាតស្រូវ ១២ម៉ឺនហិចតា ។

សម្តេចហ៊ុន សែន ប្រមុខរដ្ឋាភិបាលកម្ពុជា បានប្រកាសតួលេខការខូចខាត កាលពីថ្ងៃទី០១ ខែតុលា ។

សម្តេចមានប្រសាសន៍ថា គ្រោះទឹកជំនន់ឆ្នាំ២០១១នេះ ធ្ងន់ធ្ងរជាងឆ្នាំ ២០០០ ហើយបានធ្វើឱ្យរដ្ឋាភិបាលជួបការលំបាក ដោយសារទុនបម្រុងរដ្ឋសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធត្រូវបង្វែរទៅជួសជុលការខូចខាតវិញ ។

ទឹកជំនន់ធ្វើឱ្យផ្លូវជាតិ និងផ្លូវខេត្តជាង ១០០គ.ម. ផ្លូវលំ ១ ៨០០ គ.ម. ស្ពានចំនួន ១៦០ និងទំនប់មួយចំនួនត្រូវរងការខូចខាត ។ វត្តចំនួន៤០១ សាលារៀនចំនួនជាង១១៣២ និងមណ្ឌលសុខភាពចំនួន ៧៥កន្លែងក៏ត្រូវជន់ លិចផងដែរ ។

### នាយករដ្ឋមន្ត្រីថៃថ្មី មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា

លោកស្រីយីងឡាក់ ស៊ីណាវ៉ាត្រា នាយករដ្ឋមន្ត្រីថៃថ្មីបានមកទស្សនកិច្ចនៅប្រទេសកម្ពុជាកាលពីថ្ងៃទី១៥ ខែកញ្ញា ។ លោកស្រីបានជួបធ្វើសវនាការ និងចូលគាល់ព្រះមហាក្សត្រកម្ពុជា និងជួបប្រមុខរដ្ឋាភិបាលកម្ពុជា ។

ឯកឧត្តមហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស បានឱ្យដឹងថា នៅក្នុងជំនួបគ្នា ប្រមុខរដ្ឋាភិបាលទាំងពីរបានសន្យាអនុវត្តតាមសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ និងខិតខំជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។

### កម្ពុជារៀបចំពិព័រណ៍ផ្លែឈើ និងបន្លែ ជាលើកទីមួយ

បន្លែ និងផ្លែឈើដែលដាំដោយកសិករខ្មែរ ដូចជាផ្លែក្រូចពោធិ៍សាត់ ចេក និងបន្លែផ្សេងៗ មានសាឡាត់ ត្រកួន ការ៉ុត ប៉េងបោះ... ត្រូវបានបង្ហាញនៅក្នុងពិព័រណ៍មួយពីថ្ងៃទី១-២ ខែតុលា នៅសណ្ឋាគារកាំបូឌីយ៉ា-ណា រាជធានីភ្នំពេញ ។

ក្នុងពិធីបើក ឯកឧត្តមចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍ថា ពិព័រណ៍នេះគឺជាការបង្ហាញពីការខិតខំប្រឹងប្រែងក្នុងការជំរុញ និងលើកកម្ពស់ផលិតផលបន្លែ និងផ្លែឈើខ្មែរ ឱ្យមានលទ្ធភាពធ្វើចរាចរណ៍នៅទីផ្សារនានានៅក្នុងស្រុក ដើម្បីជំនួសការនាំចូលជាបណ្តើរៗ ។ ឯកឧត្តមបញ្ជាក់ថា៖ "ការតាំងបង្ហាញនេះ គឺជាសារមួយបង្ហាញថា បន្លែ និងផ្លែឈើកម្ពុជា គឺជាផលិតផលដែលមានគុណភាព និងមានលក្ខណៈធម្មជាតិល្អជាងបន្លែ និងផ្លែឈើ ដែលនាំចូលពីបរទេស" ។

### ចិនសម្ពោធយានអវកាសថ្មីរបស់ខ្លួន

បណ្តាញព័ត៌មានឆាណែល ញូវអាស៊ី កាលពីចុងខែកញ្ញាកន្លងទៅ បានឱ្យដឹងថា ប្រទេសចិនទើបតែសម្ពោធនូវយានអវកាសដ៏ថ្មីស្រឡាងរបស់ខ្លួននៅក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍវិស័យអវកាសរបស់ខ្លួន។

លោកហូ ចិនតាវ ប្រធានាធិបតីចិន បានសន្យាថា នឹងធ្វើឱ្យមានភាពជោគជ័យនូវកិត្តិនាមរបស់ចិន ក្រោយពេលដែលសម្ពោធយានអវកាសថ្មីនេះ។

យោងតាមប្រភពដដែលនោះ បានឱ្យដឹងថា យានអាវកាសថ្មីនេះ ត្រូវបានគេដាក់ឈ្មោះថា ធៀនហ្គង់-១ ហើយគោលបំណងដែលចិនបានជំរុញការផលិតយានអវកាសនេះ គឺសម្រាប់ធ្វើការស្រាវជ្រាវទិន្នន័យ និងស៊ើបការណ៍នៅលើលំហអវកាស។

ប្រភពដដែលនោះបានឱ្យដឹងទៀតផងដែរថា យានអាវកាសធៀនហ្គង់-១នេះ គឺជាយានមួយដែលមានសមត្ថភាពធ្វើដំណើរឆ្ពោះទៅកសាងស្ថានីយអវកាសដ៏ធំដំបូងរបស់ចិននៅក្នុងថ្ងៃអនាគត។

កាលពីឆ្នាំ២០០៣កន្លងទៅ ប្រទេសចិនបានបញ្ជូនអាកាសយានិករបស់ខ្លួនទៅកាន់ទីអវកាសបានយ៉ាងជោគជ័យ។ អវកាសយានិកដំបូងរបស់ចិនដែលធ្វើសម្រេចបេសកកម្មនេះ គឺលោកយ៉ាង លីវេ។

### រុស្ស៊ីទទួលជោគជ័យលើការបាញ់បង្ហោះមីស៊ីលថ្មី

កាលពីថ្ងៃទី២៩ ខែកញ្ញា កន្លងទៅនេះ រុស្ស៊ីបានអះអាងអំពីភាពជោគជ័យលើការសាកល្បងនៅក្នុងការបាញ់បង្ហោះនូវមីស៊ីលថ្មីរបស់ខ្លួន ដែលមានឈ្មោះថា លីន័រ ។

យោងតាមទីភ្នាក់ងារព័ត៌មានចិនស៊ីនហួរ បានឱ្យដឹងដែរថា ប្រភេទមីស៊ីលលីន័រនេះ ជាប្រភេទមីស៊ីលថ្មី មានសមត្ថភាពក្នុងការហោះបានរយៈចម្ងាយឆ្ងាយ ដើម្បីផ្តិតយកព័ត៌មានតាមបែបវិទ្យាសាស្ត្រ ។

លោកអ៊ីហ្គ័រ កូណាសឆេនកូវ ជាអ្នកនាំពាក្យក្រសួងការពារជាតិនៃប្រទេសរុស្ស៊ី បានមានប្រសាសន៍ថា កាំជ្រួចមីស៊ីលថ្មីនេះត្រូវបានបាញ់បង្ហោះពីរោងចក្រនុយក្លេអ៊ែរ ដែលស្ថិតនៅតំបន់សមុទ្របារ៉េន ។

លោកអ៊ីហ្គ័រ កូណាសឆេនកូវ បានឱ្យដឹងថា កាំជ្រួចថ្មីនេះគឺនឹងជួយប្រតិបត្តិការការងាររបស់រុស្ស៊ីនៅក្នុងលំហអាកាសបានយ៉ាងងាយស្រួល និងទាន់ពេលវេលា ។ លោកបន្តថា នេះជាសមិទ្ធផលមួយថ្មីនៃកិច្ចខិតខំប្រឹងប្រែងរបស់រុស្ស៊ី នៅក្នុងកម្មវិធីធ្វើទំនើបកម្មសម្ភារៈយោធារបស់ប្រទេសខ្លួន ចាប់តាំងពីវិស័យនេះបានធ្លាក់ចុះកាលពីទសវត្សរ៍មុន ។



Photo : DR

# បណ្ឌិតសភាចារ្យ ចន្ទ្រាបុត្រ : "មនុស្សខ្មែរចាប់ផ្ដើមទទួលស្គាល់តម្លៃនៃឧត្ដមគតិ និងការអប់រំ"

**ខាន់ ភីរម្យ**

*ប្រជាពលរដ្ឋខ្មែរសម័យបច្ចុប្បន្ននេះ ចាប់ផ្ដើមឱ្យតម្លៃ និងទទួលស្គាល់តម្លៃនៃឧត្ដមគតិ និងការអប់រំធំជាងតម្លៃនៃសម្ភារៈបណ្ដើរៗ ហើយដើម្បីឱ្យដឹងថា តើហេតុផលអ្វីបានជាពលរដ្ឋខ្មែរឱ្យតម្លៃទៅលើសម្ភារៈ ហើយនៅពេលនេះបែរជាចាប់ផ្ដើមឱ្យតម្លៃទៅលើការអប់រំវិញនោះ អ្នកនាំសារសូមណែនាំមិត្តអ្នកអានឱ្យជួបជាមួយនឹងលោករស់ ចន្ទ្រាបុត្រ បណ្ឌិតសភាចារ្យ ទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។*



Photo : S. Philong

**អ្នកនាំសារ : នាពេលបច្ចុប្បន្ននេះ អ្នកនាំសារ និងប្រជាពលរដ្ឋយើង មើលឃើញថា ពលរដ្ឋភាគច្រើន គឺឱ្យតម្លៃទៅលើកត្តាសម្ភារៈ តើលោកបណ្ឌិតយល់ឃើញយ៉ាងណាដែរ ?**

**លោករស់ ចន្ទ្រាបុត្រ** : នេះគឺជាការពិត។ ប៉ុន្តែសង្គមចាប់ផ្ដើមមានការផ្លាស់ប្ដូរបណ្ដើរៗ។ ការដែលមនុស្សច្រើនឱ្យតម្លៃទៅលើកត្តាសម្ភារៈនោះ ជាកត្តាធម្មជាតិរបស់មនុស្ស ដោយសារតែមនុស្សត្រូវការនូវអ្វីដែលថ្មី ដើម្បីបង្ហាញប្រាប់អ្នកដទៃឱ្យឃើញអំពីអំណាច និងភាពល្បីល្បាញរបស់ខ្លួន ឬដើម្បីឱ្យខ្លួនមានមុខមាត់នៅក្នុងសង្គម។

**អ្នកនាំសារ : ការដែលសង្គមឱ្យតម្លៃទៅលើកត្តាសម្ភារៈនិយមបែបនេះ តើវាជាប្រការល្អសម្រាប់សង្គមដែរឬទេ?**

**លោករស់ ចន្ទ្រាបុត្រ** : ក្នុងករណីដែលសង្គមឱ្យតម្លៃទៅលើកត្តាសម្ភារៈនិយមនេះខ្លាំងពេក វាជាការព្រួយបារម្ភមួយ ពីព្រោះដើម្បីឱ្យខ្លួនក្លាយខ្លួនជាមនុស្សល្បីល្បាញបានមនុស្សខ្លះដែលខ្វះការត្រិះរិះពិចារណា និងខ្វះការអប់រំ អាចនឹងប្រើប្រាស់នូវទង្វើអសីលធម៌ណាមួយ ដើម្បីធ្វើយ៉ាងណាឱ្យខ្លួនលេចធ្លោឡើង។ ប៉ុន្តែនៅសង្គមខ្មែរ នាសម័យនេះគេចាប់ផ្ដើមមានការយល់ដឹងឡើងវិញជាបណ្ដើរៗ ហើយ ដោយសារមនុស្សភាគច្រើន បានទទួលការអប់រំ និងមានឧត្ដមគតិ។

**អ្នកនាំសារ : តើកត្តាដែលនាំមនុស្សខ្មែរនិយមឱ្យតម្លៃទៅលើកត្តាសម្ភារៈនេះ គឺដោយសារតែអ្វីទៅ ហើយមកដល់ពេលនេះ តើហេតុអ្វីបានជាសង្គមខ្មែរចាប់ផ្ដើមឱ្យតម្លៃទៅលើឧត្ដមគតិ និងការអប់រំទៅវិញនោះ ?**

**លោករស់ ចន្ទ្រាបុត្រ** : កត្តាដ៏ចម្បងដែលធ្វើឱ្យសង្គមខ្មែរតែងឱ្យតម្លៃទៅលើកត្តាសម្ភារៈនោះ គឺដោយសារតែសង្គ្រាមស៊ីវិលជាពិសេស គឺរបបខ្មែរក្រហម ដែលធ្វើឱ្យកោសិកាសង្គម និងមនុស្សខ្មែរនៅពេលនោះត្រូវបំផ្លាញស្ទើរតែទាំងស្រុង។ បន្ទាប់មកទៀត គឺមានកត្តាធ្លាក់ចុះនូវសីលធម៌ និងកង្វះខាតការអប់រំ។ ប៉ុន្តែក្រោយអំពីសង្គ្រាមស៊ីវិលបានបញ្ចប់នៅចុងឆ្នាំ១៩៩៨ ជាង១០ឆ្នាំ កន្លងមកនេះការអប់រំបានត្រូវពង្រឹង ទើបមនុស្សខ្មែរចាប់ផ្ដើមទទួលស្គាល់ សីលធម៌ ឧត្ដមគតិ និងការអប់រំវិញ។

**អ្នកនាំសារ : តើនឹងមានគ្រោះថ្នាក់យ៉ាងណាប្រសិនបើសង្គមមួយនៅតែឱ្យតម្លៃទៅលើកត្តាសម្ភារៈនោះ ?**

**លោករស់ ចន្ទ្រាបុត្រ** : ប្រសិនបើសង្គមនៅបន្តឱ្យតម្លៃទៅលើកត្តាសម្ភារៈនេះ ដ៏ជ្រុលហួសហេតុពេក វានឹងអាចធ្វើឱ្យសង្គមជួបគ្រោះថ្នាក់ ដោយសារតែសង្គមនេះខ្វះខាតនូវវិន័យ ពីព្រោះដោយ-សារសម្ភារៈ មនុស្សមួយចំនួនប្រើប្រាស់នូវអំណាចហិង្សា ខុសច្បាប់ ឬរំលោភសិទ្ធិ...។ សង្គមនឹងផុយស្រួយ ដែលងាយធ្វើឱ្យប្រទេសជាតិបាត់ព្រលឹង។



Photo : L. Samphors

## ព្រលឹងជាតិសាសន៍មួយ

លោករស់ ចន្ទ្រាបុត្រ មានប្រសាសន៍ថា ព្រលឹងរបស់ជាតិសាសន៍មួយ គឺស្ថិតនៅលើភាសា ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ និងប្រវត្តិសាស្ត្រ។

លោកបន្តថា ដើម្បីការពារព្រលឹងនេះ ពលរដ្ឋខ្មែរត្រូវតែចេះការពារ និងឱ្យតម្លៃទៅលើភាសាជាតិ ស្គាល់វប្បធម៌ ប្រពៃណីទំនៀមទម្លាប់របស់ខ្លួន និងចងចាំនូវប្រវត្តិសាស្ត្ររបស់ជាតិ។ ប្រសិនបើពលរដ្ឋម្នាក់ៗ កើតមកអត់ចេះភាសាខ្លួន អត់ស្គាល់ប្រវត្តិសាស្ត្រខ្លួនហើយ គាត់គឺដូចជាជាតិសាសន៍មួយដែលអត់មានព្រលឹង។

លោករស់ ចន្ទ្រាបុត្របញ្ជាក់ថា : "ពលរដ្ឋម្នាក់ ដែលស្គាល់ព្រលឹងខ្លួនឯងច្បាស់ ទាល់តែគាត់មានការអប់រំ តាំងពីកុមារភាព"។

## បទយកការណ៍

# ពលរដ្ឋគាំទ្រ និងសូមឱ្យពង្រឹងគោលនយោបាយភូមិ–

**ខាន់ ភីរម្យ**

ប្រជាពលរដ្ឋទូទៅគាំទ្រទាំងស្រុង ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ប្រើប្រាស់នូវគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពដើម្បីអនុវត្តនៅទូទាំងប្រទេស។ ប៉ុន្តែប្រជាពលរដ្ឋបានស្នើសុំឱ្យអាជ្ញាធរពង្រឹងជាបន្ថែមទៀតលើការអនុវត្តនូវគោលនយោបាយនេះ។

លោកជេត សីហា ប្រជាពលរដ្ឋមួយរូបរស់នៅសង្កាត់ទឹកល្អក់ទី៣ រាជធានីភ្នំពេញ បានឱ្យដឹងថា នេះគឺជាគោលនយោបាយមួយដ៏ល្អ ហើយសមស្របនឹងកាលៈទេសស្រុកទេសយើងសព្វថ្ងៃនេះ។ ប៉ុន្តែកន្លងមកការអនុវត្តនយោបាយនេះហាក់ដូចជានៅមិនទាន់អាចធានាបានសន្តិសុខ-សុវត្ថិភាពនៅក្នុងប្រទេសបានទាំងស្រុងនៅឡើយទេ។ លោកបានក៏បញ្ជាក់ថា: "ខ្ញុំសង្កេតឃើញថាសកម្មភាព ឬអំពើអបាយមុខ បងតូច បងធំ និងការជួយដូរគ្រឿងញៀន គឺថយចុះច្រើន ក្រោយពីអាជ្ញាធរដាក់ចេញនូវគោលនយោបាយនេះមក"។ លោកបន្តទៀតថា មកដល់សព្វថ្ងៃនេះ ចំពោះចលនាបងតូចបងធំ និងការជួញដូរគ្រឿងញៀន នៅតាមមូលដ្ឋាន យើងក៏ឃើញថា អាជ្ញាធរមានសមត្ថកិច្ច ហាក់ដុតដៃ ដុតជើងបង្ក្រាបច្រើន។ ប៉ុន្តែសម្រាប់ករណីឧក្រិដ្ឋកម្មផ្សេងៗ ដូចជា ចោរកម្ម ចោរប្លន់ ឃាតកម្មផ្សេងៗ នៅតែបន្តកើតមានជាបន្តបន្ទាប់។

លោកកាន សុភត្រា អ្នករត់ម៉ូតូឌុប វ័យ ៤០ឆ្នាំមួយរូប ក៏បានឱ្យដឹងថា មួយរយៈពេលចុងក្រោយនេះអំពើចោរកម្ម ប្លន់ម៉ូតូ គឺដូចជាលែងស្ងួវញួសួរ។ ភាគច្រើនឮតែប្លន់ អ្នកលក់មាស តាមផ្ទះ តាមអីនៅឮសួរខ្លះៗប៉ុណ្ណោះ។ លោកបញ្ជាក់ថា: "សព្វថ្ងៃនេះ គេដើរលេងទើសៗភ្លឺ ហើយអ្នកខ្លះគេរត់ម៉ូតូឌុបតែយប់ទេ ហើយម៉ូតូសុទ្ធតែអាសង់ "០១០" ក៏មានដែរ បើពីមុនវិញអត់បានទេត្រឹមតែអាសង់កូរ៉េក៏ឮស្ងួរចោរបាញ់ប្លន់ដែរ"។ លោកសុភត្រា មកពីខេត្តព្រៃវែងរូបនេះបានបន្តដែរថា នៅស្រុកលោកអំពើហិង្សា ដូចជាមានការថយចុះច្រើន។ លោកក៏បន្ថែមថា នៅតាមស្រុកភូមិ ឥឡូវនេះ ពេលបុណ្យទាន ដូចជាមិនសូវមានការកាប់ចាក់គ្នាទេ។

អាជីវករដូរលក់មាស និងប្តូរប្រាក់មួយរូប នៅផ្សារដីហុយក្រុងភ្នំពេញ ដែលសុំមិនបញ្ចេញឈ្មោះ បានឱ្យដឹងថា គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពអ្វីគាត់មិនដឹងទេ។ ប៉ុន្តែសព្វថ្ងៃនេះគាត់នៅពុំមានអារម្មណ៍ស្ងប់ចិត្តនៅក្នុងការប្រកបរបរឡើយ ដោយសារបារម្ភអំពីសុវត្ថិភាព។ លោកស្រីនិយាយថា: "ការពារឬមិនការពារស្អីគឺមិនសំខាន់ទេ។ តែឥឡូវនេះអ្នកលក់មាសភ្នែកនៅតែកញ្ជឹងក។ ព័ត៌មានចោរប្លន់ គឺបាញ់សម្លាប់ស្រស់ៗណាស់"។

គោលនយោបាយភូមិ-ឃុំសុវត្ថិភាព គឺជាគោលនយោបាយមួយដែលប្រកាសអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងសំខាន់ គឺសំដៅទៅលើការផ្តល់ និងការពារសេចក្តីសុខសាន្តសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋ ក៏ដូចជាការពារទ្រព្យសម្បត្តិសាធារណៈរបស់ជាតិនិងសម្បត្តិឯកជន។ ប៉ុន្តែការអនុវត្តនូវគោលនយោបាយនេះ គឺនៅមិនទាន់បាន

### គោលនយោបាយភូមិ–ឃុំមានសុវត្ថិភាព

លោកទូច ចាន់ថន ចៅសង្កាត់ផ្សារដេប៉ូ២ បានមានប្រសាសន៍ឱ្យដឹងថា គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាពនេះ គឺមាន ៥ចំណុចធំៗ ដែលរួមមានសំដៅធានាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមនៅក្នុងមូលដ្ឋាន។

លោកបញ្ជាក់ថា ចំណុចទីមួយ គឺធ្វើឱ្យមូលដ្ឋានគ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ។ ចំណុចទី២ គឺជំរុញឱ្យមូលដ្ឋានគ្មានការផលិត ការចែកចាយ និងការប្រើប្រាស់គ្រឿង ញៀនខុសច្បាប់។ ចំណុចទី៣ នោះ គឺធ្វើឱ្យមូលដ្ឋានគ្មានអំពើអានាចារ ការជួញដូរស្ត្រីកុមារ និងអំពើហិង្សាក្នុងគ្រួសារ។ ចំណុចទី៤ គឺបង្កលក្ខណៈលុបបំបាត់ចោលនូវក្មេងទំនើងនៅក្នុងមូលដ្ឋាន។ ហើយចំណុចចុងក្រោយនោះ គឺធ្វើឱ្យមូលដ្ឋានគ្មានការលេងល្បែងស៊ីសង ខុសច្បាប់ គ្រប់ប្រភេទ គ្មានការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសផ្សេងៗ។

លោកបានឱ្យដឹងថា អាជ្ញាធរកំពុងតែប្រឹងប្រែងធ្វើឱ្យសម្រេចគោលនយោបាយនេះ។



# ឃុំមានសុវត្ថិភាពបន្ថែមទៀត

ធានាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គមបាន ១០០% នៅឡើយទេ ពោលគឺវាទាមទារនូវពេលវេលា ជាបន្ថែមទៀត ។នេះបើតាមការអះអាងរបស់អាជ្ញាធរដែលធ្វើការងារនៅមូលដ្ឋាន ។

លោកច័ន្ទ ហៃ ចៅសង្កាត់ទឹកល្អក់ទី៣ ស្ថិតនៅខណ្ឌទួលគោក រាជធានីភ្នំពេញ បានមានប្រសាសន៍ឱ្យដឹងថា បញ្ហានៅមិនទាន់ដោះស្រាយបានទាំងស្រុងទេ ។ ប៉ុន្តែវាបានប្រសើរច្រើនណាស់ ។ លោកបានឱ្យដឹងថា កាលដើមឡើយនៅពេលដែលរដ្ឋាភិបាលមិនទាន់ដាក់ចេញនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនេះឡើងនៅក្នុងសង្កាត់ទឹកល្អក់ទី៣ មានបញ្ហាច្រើន ដូចជា ក្មេងហិតការជួបជុំគ្នាធ្វើទង្វើមិនល្អ លួចគាស់ផ្ទះសម្បែង ឆក់ប្លន់ បងធំបងតូច ដែលបង្កភាពស្មុគស្មាញដល់ប្រជាពលរដ្ឋ និងមានការរំខានដល់រស់នៅរបស់ពួកគាត់ ។ ប៉ុន្តែនៅពេលដែលរាជរដ្ឋាភិបាលបង្កើតគោលនយោបាយនេះមក យើងឃើញថានៅក្នុងសង្កាត់ទឹកល្អក់ទី៣ មានការប្រែប្រួលគួរឱ្យចាប់អារម្មណ៍ ។ប្រជាពលរដ្ឋទទួលបាននូវភាពកក់ក្តៅយ៉ាងខ្លាំង ។លោកបញ្ជាក់ថា : "អំពើពាលាអាវ៉ាសែនៃក្រុមក្មេង បងតូចបងធំបានបាត់ ។ ការលួចគាស់សម្បែងនៅមានកម្រិតតិចតួចបំផុត ។ការវាយតប់គ្នារវាងក្រុមអ្នកលេងបានថយចុះយ៉ាងច្រើន" ។ លោកបន្តថា តាមគោលនយោបាយនេះ អាជ្ញាធរមូលដ្ឋានបានបង្កើតនូវប្រជាការពារមួយចំនួន ដើម្បីបន្ថែមពីលើកម្លាំងសមត្ថកិច្ចក្នុងការបង្កើនកិច្ចសហការការពារតាមគោលដៅនៅក្នុងមូលដ្ឋាន ។

លោកទូច ចាន់ថន ចៅសង្កាត់ផ្សារដេប៉ូ២ បានឱ្យដឹងថា តាមគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនេះ សង្កាត់របស់លោកក៏បានបញ្ចូលនូវប្រជាការពារបន្ថែមលើកម្លាំងប៉ូលិសក្នុងមូលដ្ឋានដែរ ។ ហើយក្រៅពីនេះ សង្កាត់ក៏បានធ្វើការចែកចាយនូវលេខទូរស័ព្ទដល់ប្រជាពលរដ្ឋសម្រាប់ទាក់ទង មកខាងសមត្ថកិច្ចពេលមានបញ្ហា ឬក៏មានជនសង្ស័យណាមួយដែលបង្កឱ្យមាននូវបញ្ហាផ្សេងៗ ដើម្បីឱ្យខាងសមត្ថកិច្ចអាចចុះចាត់វិធាន ការបានយ៉ាងឆាប់រហ័ស និងទាន់ពេលជូនដល់ពួកគាត់ ។

ជុំវិញបញ្ហានេះ ប្រជាការពារមួយរូបបានឱ្យដឹងថា ការងារនេះ គាត់ទទួលបានតាមរយៈការស្ម័គ្រចិត្តដោយជាថ្នូរ និងការឧបត្ថម្ភជាប្រាក់បៀវត្សជាប្រចាំខែពីប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋាន និងពីចៅសង្កាត់ ។ លោកលឹម គុន្ធា អាយុ ៤២ឆ្នាំ ដែលជាប្រជាការពារស្ម័គ្រចិត្តប្រចាំនៅសង្កាត់ទឹកល្អក់ទី៣ ក៏បានឱ្យដឹងថាលោកបានចូលបម្រើការងារនេះបានមួយឆ្នាំហើយ ។ លោកពេញចិត្តទៅនឹងការងារនេះខ្លាំងណាស់ ព្រោះជាការងារមួយដែលបានផ្តល់សេចក្តីសុខដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់លោកផ្ទាល់តែម្តង ។ លោកក៏បានបន្តទៀតថា នៅក្នុងនាមជាប្រជាការពារ គឺយើងមានភារៈកិច្ចស្នូលគឺការពារសន្តិសុខនិងសុវត្ថិភាព នៅក្នុងតំបន់ដែលយើងទទួលខុសត្រូវ នៅក្នុងករណីមានហេតុការណ៍ណាមួយ ឬមានជនណាម្នាក់ចម្លែកនៅក្នុងមូលដ្ឋាន យើងរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចដែលជាមន្ត្រីជំនាញចុះប្រតិបត្តិការ ។ លោកបានឱ្យដឹងថា ពេលបំពេញភារៈកិច្ច ម្នាក់ៗគឺមានឯកសណ្ឋាន និងមានដំបងមួយនិងអាយឌី(វិទ្យុទាក់ទង) ដើម្បីធ្វើការរាយការណ៍ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច ។ លោកបញ្ជាក់ថា : "យើងផ្លាស់ប្តូរវេនគ្នាយាមការពារ តំបន់របស់យើង ២៤ម៉ោង" ។

តាមប្រសាសន៍របស់លោកចៅសង្កាត់ទាំងពីរខាងលើ ការបង្កើតនៅប្រជាការពារនៅតាមមូល-ដ្ឋាន មិនមានកំណត់ចំនួនច្បាស់លាស់ទេ អាស្រ័យទៅតាមមូលដ្ឋាន និងសំណូមពរអំពីប្រជាពលរដ្ឋ-ផ្ទាល់នៅក្នុងមូលដ្ឋាន ។ ជាក់ស្តែងនៅសង្កាត់ទឹកល្អក់ទីបី គេបានបង្កើតក្រុមប្រជាការពារ នេះចំនួន ៨នាក់ ហើយនៅក្នុងសង្កាត់ផ្សារដេប៉ូ២ គឺគេមានសមាជិក ១១នាក់ ។

ចំណែកលោកជេត សីហា ជាប្រជាពលរដ្ឋ បានប្រាប់ឱ្យដឹងទៀតថា ដើម្បីធានាជូននូវសន្តិសុខ និងសុវត្ថិភាពដល់ប្រជាពលរដ្ឋអាជ្ញាធរមូលដ្ឋាន គឺគួរពង្រឹងតួនាទីបន្ថែមទៀតទៅតាមគោលភូមិ-ឃុំមានសុវត្ថិភាព នៅខណៈដែលលោកស្រីអាជីវករលក់មាសខាងលើជំរុញឱ្យមានការពង្រឹងសមត្ថ-ភាពរបស់ប្រជាការពារបន្ថែមទៀត ។

លោកស្រី បាននិយាយថា នៅតាមទីផ្សារមានប៉ូលិស ឬប្រជាការពារ ស្រាប់តែចោរប្លន់ ។ វាអត់ខ្លាចសមត្ថកិច្ចទាល់តែសោះ ។



Photo : S. Philong

## ករណីបាញ់ប្រហារគួរឱ្យកត់សម្គាល់នាដើមខែតុលា

ស្ត្រីវ័យក្មេងអាយុ ២៣ឆ្នាំមួយរូប បានរងនូវការបាញ់ប្រហារពីសំណាក់ឃាតករហូតដល់បាត់បង់ជីវិតនៅនឹងកន្លែង នៅក្នុងខណៈពេលដែលកំពុងតែនាំកូនដែលមានអាយុត្រឹមតែ ៣ខែ ទៅចាក់ថ្នាំការពារ។

អំពើបាញ់ប្រហារនេះបានកើតមានឡើងកាលពីថ្ងៃទី០៣ ខែតុលា នៅបរិវេណមណ្ឌលសុខភាពចំការដូង នៅភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ជនរងគ្រោះត្រូវបានឃាតករបាញ់ចំនួនបីគ្រាប់ ដោយមួយគ្រាប់មិនចំ គ្រាប់ទី២ ត្រូវប្រឆិតស្មា ហើយទីបីត្រូវចំក្បាល ស្លាប់នៅហ្នឹងកន្លែង នៅមុនពេលដែលជនសង្ស័យទាញម៉ូតូ មួយគ្រឿង ម៉ាកសេ ១២៥ ស៊េរី២០១១ ជិះរត់គេចខ្លួនដោយមានសុវត្ថិភាព។

នៅជំហានដំបូង ប៉ូលិសសន្និដ្ឋានថា អំពើបាញ់ប្រហារនេះ គឺដោយសារតែស្នេហាត្រីកោណ។ ស្ត្រីជនរងគ្រោះបានរៀបការជាមួយនិងអាណិកជនមកពីប្រទេសញូវសេឡេន ម្នាក់ដែលគេដឹងថា មានភរិយាទៅហើយនោះ។

# ព័ត៌មានព្រះសហគមន៍កាតូលិក

## ជនរងគ្រោះដោយជំនន់ទឹកភ្លៀង នៅកំពង់ធំ ទទួលជំនួយ

ភ្លៀងធ្លាក់ជាបន្តបន្ទាប់កាលពីចុងខែកញ្ញា បាន ធ្វើឱ្យប្រជាពលរដ្ឋជាច្រើន ដែលមានប្រមាណ ជា ៥០១ គ្រួសារ បានរងគ្រោះ និងបញ្ហាខ្វះ ទីជម្រក នៅតំបន់ព្រះសហគមន៍ ខេត្តកំពង់ធំ ។

លោកបូជាចារ្យចាប់ អ្នកទទួលខុសត្រូវនៅព្រះសហគមន៍កំពង់គោ ខេត្តកំពង់ធំ ក៏មានប្រសាសន៍ថា នៅពេលនេះ មានបងប្អូនក្រីក្រជាច្រើនគ្រួសារ កំពុងតែស្វែងរកទីជម្រកស្នាក់នៅបណ្ដោះអាសន្ន ដ្បិតផ្ទះសម្បែងរបស់ពួកគាត់ ទទួលការលិចលង់ក្នុងកម្ពស់ទឹក ប្រមាណជា ២ម៉ែត្រកន្លះ ហើយជាបណ្ដោះអាសន្ន គ្រួសារមួយចំនួនមករស់ នៅក្នុងសាលាមត្តេយ្យរបស់ព្រះវិហារកំពង់គោ និងសាលាអនុវិទ្យាល័យកំពង់គោ ខេត្តកំពង់ធំផងដែរ ។

លោកបូជាចារ្យចាប់ ក៏បន្តឱ្យដឹងទៀតថា នៅពេលនេះ ព្រះសហគមន៍មិនអាចជួយអ្វីបាន ច្រើននោះទេ ក្រៅពីការដើរមើលស្ថានភាព និងជួយដឹកជញ្ជូនសម្ភារះរបស់ប្រជាជនរងគ្រោះទៅកាន់ទីទួល ដែលមានសុវត្ថិភាព និងការផ្ដល់កន្លែងស្នាក់អាស្រ័យតាមដែលអាចផ្ដល់ឱ្យបាន ។

ទន្ទឹមពេលនោះ លោកក៏បានបញ្ជាក់ផងដែរថា កាលពីថ្ងៃសុក្រទី២៣ ខែកញ្ញានេះ អង្គការការិតាស បានធ្វើការផ្គត់ផ្គង់គ្រឿងឧបភោគ និងបរិភាគមួយចំនួនទៅដល់ប្រជាពលរដ្ឋចំនួន ១២៣០ គ្រួសារ ដោយក្នុងនោះ រួមមានអង្ករ និងគ្រឿងទេសផ្សេងៗ ។ ក្នុងមួយគ្រួសារទទួលបានអង្ករ២៥ គីឡូក្រាម ទឹកត្រី ១លីត្រ ស្ករស មួយគីឡូក្រាម អំបិលមួយកញ្ចប់ សាប៊ូមួយដុំ សាប៊ូម្សៅមួយគីឡូ និងត្រីខមួយយួរ ១០ កំប៉ុង ដែលនេះគឺជាការជួយសម្រាលដល់ការលំបាករបស់បងប្អូនផងដែរ ។

សូមបញ្ជាក់ផងដែរថា កាលពីចុងខែកញ្ញាជំនន់ទឹកភ្លៀងបានធ្វើឱ្យប៉ះពាល់ដល់ខេត្តចំនួន១៦ នៅជុំវិញបឹងទន្លេសាប និងទន្លេមេគង្គដែលធ្វើឱ្យមានមនុស្សស្លាប់ ២០៦នាក់ និងផ្ទះសម្បែង ២២៣ខ្ទង ត្រូវខូចខាត ។

**សុខន**

## សកម្មភាពក្រុមយុវជនបាត់ដំបងមុនថ្ងៃបុណ្យភ្ជុំបិណ្ឌ

ក្នុងរយៈពេលបួនថ្ងៃមុនពិធីបុណ្យភ្ជុំ ឈានមកដល់នៅថ្ងៃទី២៧ ខែកញ្ញា ព្រះសហគមន៍កាតូលិកបាត់ដំបង ហៅថាពេទ្យយាយជី ក្នុងក្រុងបាត់ដំបង ខេត្តបាត់ដំបង មានរៀបចំការដឹកនាំ ក្រុមយុវជនឱ្យធ្វើការជម្រះស្មៅ និងសំអាតនៅបរិវេណដីព្រះពរ និងលាបពណ៌ថ្មីដល់ចេតីយរបស់គ្រីស្តទូត ។

លោកអាន រិទ្ធីវ័ត្ន ជាប្រធានក្រុមយុវជន បាននិយាយថា យើងធ្វើការរៀបចំនេះ គឺដើម្បីត្រៀមលក្ខណៈសម្រាប់ថ្ងៃបុណ្យភ្ជុំទី២៦ ដែលនឹង ឈានមកដល់ ។ នៅពេលនោះនឹង មានការដុតទៀននៅជុំវិញបរិវេណដីព្រះពរ និងចេតិយនៃគ្រីស្តបរិស័ទ ហើយនិងការប្រោសទឹកព្រះពរពីសំណាក់លោកបូជាចារ្យ និងកម្មវិធីថ្វាយអភិបូជារួមគ្នាផងដែរ ។

តាមទម្លាប់ បងប្អូនគ្រីស្តបរិស័ទគឺអាចនឹងយកបាយសម្ល និងនំចំណីទៅកាន់ព្រះវិហារដើម្បីទទួលទានអាហាររួមគ្នាផងដែរ ។

ជាធម្មតាកម្មវិធីនេះ គឺតែងរៀបចំ ឡើងរៀងរាល់ឆ្នាំ នៅព្រះសហគមន៍កាតូលិកបាត់ដំបងដែលស្ថិត នៅភូមិរំចេកមួយ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

**សុខន**



Photo : Rihtyrath

## ព្រះវិហារសន្តយ៉ូសែបជួយដល់ជនរងគ្រោះដោយទឹកជំនន់



Photo : V. Sambath

ប្រជាពលរដ្ឋប្រមាណ ៥០០គ្រួសារ ដែលរងគ្រោះដោយទឹកជំនន់ បានទទួលគ្រឿងឧបភោគបរិភោគ និងជំនួយផ្សេងៗពីព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី៧ ខែតុលា ។

កម្មវិធីនេះ គឺបានដំណើរការប៉ុន្មានថ្ងៃនៅក្នុង សប្ដាហ៍នោះ ។ ក្នុងនោះ នៅថ្ងៃសុក្រទី៧ ខែតុលា ព្រះវិហារសន្តយ៉ូសែបបានបន្តការចុះចែកអំណោយ ដែលមានគ្រឿងឧបភោគទាំងនោះ រួមមាន អង្ករ ទឹកស៊ីអ៊ីវ មី ស្ករស និងទឹកត្រី... ដល់គ្រួសារដែលកំពុងតែរងគ្រោះដោយសារទឹកជំនន់នៅព្រះសហគមន៍កាតូលិកកោះនរា ដែលរួមមានទាំងគ្រួសារគ្រីស្តបរិស័ទ និងគ្រួសារពុទ្ធបរិស័ទផងដែរ ។

លោកបូជាចារ្យប្រ៊ុយណូ កូសម៍ ដែលជាអ្នកទទួលខុសត្រូវកម្មវិធីនេះ និងអ្នកទទួលខុសត្រូវនៅព្រះវិហារសន្តយ៉ូសែប ក៏បានមានប្រសាសន៍ឱ្យដឹងថា គ្រឿងឧបភោគបរិភោគអស់ទាំងនេះ ទទួលបានការចូលរួមជាថវិកាពីគ្រីស្តបរិស័ទ ។ កន្លងមក គឺយើងបានចែកដល់បងប្អូនដែលរស់នៅតាមបណ្ដោយដងទន្លេក្នុងនោះ គឺរួមមានព្រះសហគមន៍ពោធិ៍ធំ ក្ដីកណ្ដាល តាស្គូ កោះនរា និងតួតាំង... ។ លោកបូជាចារ្យបន្តទៀតថា ការផ្ដល់ជំនួយនឹងអាចបន្តធ្វើទៀត បើស្ថានភាពនៅតែមិនល្អប្រសើរនោះ ហើយក្រោយពេលទឹកស្រកទៅវិញនោះ គឺយើងត្រូវមើលដែរថាតើព្រះសហគមន៍អាចជួយអ្វីបន្ថែម និងតម្រូវការអ្វីជាចាំបាច់ ដំបូងគេសម្រាប់គ្រួសារជនរងគ្រោះ ។

**សុខន**

## ការយកចិត្តទុកដាក់នឹងមនុស្សចាស់នៅកំពង់ចាម

កម្មវិធីនៃទិវាចាស់ជរាសម្រាប់មនុស្សចាស់ជរាប្រមាណ ១០០នាក់ ត្រូវបានរៀបចំដោយការសហការគ្នា រវាងក្រុមសន្តវ៉ាំងសង់ ដឺ ប៉ូល ក្រុមសន្តហ្វ្រង់ស្វ័រ អាសីសីន និងក្រុមសន្តីម៉ូលីកាកាលពីថ្ងៃទី៩តុលា នៅព្រះវិហារកំពង់ចាមក្រុង។

បើតាមការរៀបរាប់របស់លោកផាន បូរ៉ា អ្នកតំណាងក្រុមប្រឹក្សាថ្នាក់ជាតិ នៃក្រុម សន្តវ៉ាំងសង់ ដឺ ប៉ូល បានឱ្យដឹងថា កម្មវិធីសម្រាប់ចាស់ជរានេះ គឺតែងធ្វើឡើងរៀងរាល់ឆ្នាំនៅថ្ងៃទី៩ ខែតុលានៅព្រះវិហារកំពង់ចាមក្រុង។ លោកបន្តថា ចាស់ជរាទាំងនេះមកពីគ្រួសារក្រីក្រ និងខ្វះខាត ហើយ នេះគឺជាលើកទីប្រាំ សម្រាប់ការរៀបចំដំណើរការ នៃកម្មវិធីដែលមានល្បែងកំសាន្ត និងការពិសារអាហាររួមគ្នា។ លោកបន្ថែមថា ជាមួយនិងគោលបំណងនៃការរៀបចំកម្មវិធីនេះឡើងនោះ ដោយសារព្រះសហគមន៍យល់ឃើញថា ភាពយកចិត្តទុកដាក់ និងក្តីស្រឡាញ់ គឺបុគ្គលគ្រប់រូបតែងទាមទារចង់បាន មិនថា ខ្លួនស្ថិតនៅវ័យណាឡើយជាពិសេសមនុស្សចាស់តែម្តង។ ម្យ៉ាងទិវានេះក៏ធ្វើឡើងដើម្បីបង្កើននូវទំនាក់ទំនងរវាងជនចាស់ជរា និងអ្នកភូមិផងឱ្យកាន់តែមានភាពល្អប្រសើរឡើងផងដែរ។

**សុខន**

## ពិធីកាន់វេនរបស់ព្រះសហគមន៍កាតូលិកក្រចេះ

ព្រះសហគមន៍កាតូលិកក្រចេះ បានរៀបចំពិធីកាន់វេន ដែលក្នុងនោះ មានការចូលរួមពីបងប្អូនដែលជាគ្រិស្តបរិស័ទចំនួន ៦នាក់ និងអ្នកកំពុងតែស្វែងយល់ចំនួន ១០នាក់ ផ្សេងទៀត កាលពីថ្ងៃទី១៣ ខែកញ្ញា មុននេះ។

ពិធីកាន់វេននេះ ត្រូវបានរៀបចំឡើងជាលើកទីពីរហើយ សម្រាប់ព្រះសហគមន៍ក្រចេះ។

ក្នុងន័យនេះ លោកបូជាចារ្យអ៊ីវ៉ាន់ កាប៉ាញ៉ាជាអ្នកទទួលខុសត្រូវនៅក្នុងព្រះសហគមន៍ក្រចេះ ក៏បានមានប្រសាសន៍ថា ការរៀបចំ ឱ្យមានពិធីកាន់វេននៅក្នុងព្រះសហគមន៍នេះ គឺយើងធ្វើឡើងក្នុងជំនឿរបស់យើងដែលជាគ្រិស្តបរិស័ទនៅក្នុងប្រពៃណីរបស់ខ្មែរ។

សកម្មភាពនេះគឺមានន័យថា ទោះបីយើងមានជំនឿមួយបែបផ្សេង។ ប៉ុន្តែការគោរពនូវប្រពៃណីខ្មែរ គឺព្រះសហគមន៍នៅតែប្រកាន់ភ្ជាប់។

យ៉ាងណាមិញ លក្ខណៈនៃការរៀបចំពិធីកាន់វេនរបស់ព្រះសហគមន៍កាតូលិក រួមមានការអធិដ្ឋានទូលអង្វរដល់ព្រះជាម្ចាស់សម្រាប់អស់បងប្អូនដែលបានចែកឋានទៅ ព្រមទាំងមានការបរិភោគអាហាររួមគ្នាផងដែរ។ កម្មវិធីនេះគឺធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ ដូចជាពិធីកាន់បិណ្ឌ ក្នុងព្រះពុទ្ធសាសនារបស់បងប្អូនខ្មែរដែរ។

**សុខន**

## កិច្ចប្រជុំរាយការណ៍ប្រចាំរបស់ក្រុមសន្តវ៉ាំងសង់ ដឺ ប៉ូល

ក្រុមសន្តវ៉ាំងសង់ ដឺ ប៉ូល មានកិច្ចប្រជុំស្តីអំពីសកម្មភាពការងារខ្លួនក្នុងរយៈពេលមួយឆ្នាំ កាលពីថ្ងៃទី១ ខែតុលា នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) នាទីក្រុងភ្នំពេញ។

កិច្ចប្រជុំនេះមានការបង្ហាញនូវលទ្ធផលការងារ ព្រមទាំងបញ្ហាប្រឈមដែលជួបនៅពេលកន្លងមកដើម្បីស្វែងរកមធ្យោបាយដោះស្រាយ និងរកវិធានការ សម្រាប់សកម្មភាពការងារដែលត្រូវបន្តធ្វើនាពេលឆ្នាំបន្តទៀត។

កិច្ចប្រជុំនេះបានធ្វើឡើងដោយមានការចូលរួមអំពីគ្រប់សមាជិកសន្តវ៉ាំងសង់ ដឺ ប៉ូល ទាំងអស់នៅតាម ព្រះសហគមន៍ទាំងបីភូមិភាគកាតូលិកនៅប្រទេសកម្ពុជា។

ក្រុមសន្ត វ៉ាំងសង់ ដឺ ប៉ូល ធ្វើការងារទាក់ទងនឹងការអភិវឌ្ឍសង្គម និងការជួយដល់អ្នកក្រីក្រជនចាស់ជរា និងកុមារ-ល-។

**សុខន**

## ព្រះសហគមន៍កោះរការរងបញ្ហាទឹកជំនន់ទន្លេមេគង្គ និងភ្លៀងក្នុងរយៈពេល ២ខែ

រយៈពេលពីខែជាប់ៗគ្នានេះ ព្រះសហគមន៍កោះរកា ភូមិភាគកាតូលិកកំពង់ចាម ទទួលរងនូវទឹកជំនន់ទន្លេមេគង្គនិងទឹកភ្លៀង។

លោកសេរ៉ាលជី វ៉ូសាំង គឺជាបូជាចារ្យទទួលខុសត្រូវប្រចាំព្រះសហគមន៍កោះរកា។ លោកមានប្រសាសន៍ថា មិនត្រឹមតែបងប្អូនគ្រិស្តបរិស័ទទេ ដែលទទួលការលំបាកផ្សេងៗ ប្រជាជននៅទីនោះ ក៏មានការលំបាកខ្លាំងផងដែរ។

លោកបានឱ្យដឹងទៀតដែរថា ក្នុងអំឡុងទឹកជំនន់នេះ ព្រះសហគមន៍បានចែកជាអង្ករម្នាក់ ៥គីឡូក្រាម និងគ្រឿងឧបភោគខ្លះៗ ដល់បងប្អូនក្រីក្រដែលកំពុងខ្វះខាតចំនួន ៧៧នាក់។ លោកបានបន្តថា បើស្ថានភាពបែបនេះនៅតែបន្តនោះ ប្រជាជនក្នុងភូមិនេះមុខជាជួបនូវបញ្ហាធំទោះបីអ្នកមានទ្រព្យ ឬគ្មានក៏ដោយ។

លោកយ៉ាន់ សុគន្ធ ជាគ្រិស្តបរិស័ទកាតូលិករស់នៅក្នុងភូមិកោះរកា បានឱ្យដឹងថា នេះគឺជាលើកទីមួយ ហើយដែលភូមិនេះរងនូវទឹកជំនន់ក្នុងរយៈពេល២ខែ។ លោកបញ្ជាក់ថា : "រាល់ដងតែកន្លងខែទៅមួយខែទេ តែពេលនេះបើរាប់ទៅតាំងពីដើមខែសីហាមកម្ល៉េះ។ ទឹកស្រកបានប៉ុន្មានថ្ងៃក៏ឡើងវិញ"។

លោកសុគន្ធ សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខភាព និងដំណាំ ស្រែចំការ ព្រោះទឹកបានជន់លិចមិនព្រមស្រកចុះសោះ សូម្បីតែដំណាំហូបផ្លែ ក៏ងាប់ខ្លះៗដែរ។ ម្យ៉ាងទៀត ទឹកជំនន់ឆ្នាំនេះ ក៏អាចបង្កឱ្យមានភាពក្រីក្រកាន់តែកើនឡើង។

នៅភូមិកោះរកា ប្រជាជនមួយភាគធំប្រកបរបរធ្វើជាកសិករ និងជាអ្នកចំការ។



Photo : Fr. Ivan

ទឹកលិចនៅតាមព្រះសហគមន៍នានាក្នុងភូមិភាគកំពង់ចាម

**កញ្ញា**

# ទឹកជំនន់នៅព្រះសហគមន៍នានានៅភូមិភាគកំពង់ចាម និងបាត់ដំបង

**ខាន់ ភីរម្យ**

ព្រះវិហារនៃព្រះសហគមន៍កាតូលិកជាច្រើនកន្លែងនៅក្នុងភូមិភាគកំពង់ចាម និងបាត់ដំបងបានទទួលការជន់លិចដោយសារទឹកជំនន់។ តែគេមិនទាន់មានព័ត៌មានអំពី ការបាត់បង់ជីវិតរបស់សមាជិក ព្រះសហគមន៍នៅឡើយទេ គិតមកដល់ត្រឹមថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១។

លោកម៉ែត វិន័យ បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ខេត្តកំពង់ធំ ភូមិភាគខេត្តបាត់ដំបង មានប្រសាសន៍ថា ក្នុងចំណោមព្រះវិហារ ៧កន្លែង នៅកំពង់ធំ លិចអស់ ៥កន្លែង។ ដីស្រែរបស់សមាជិកព្រះសហគមន៍ប្រមាណ ១១០ហិចតា ត្រូវទទួលរងការខូចខាត។ លោករៀបរាប់ថា : ″ព្រះវិហារខ្លះត្រូវជន់លិចរហូតដល់ទៅ ១,៥ម៉ែត្រ។ សមាជិកព្រះសហគមន៍ប្រមាណ ៣០០នាក់ ត្រូវរងនូវផលប៉ះពាល់″។ លោកបូជាចារ្យប្រាប់ថា កំពង់ធំទទួលរងនូវទឹកជំនន់ផ្ទួនៗនៅក្នុងឆ្នាំ២០០០ ក្រោយមកឆ្នាំ២០០៩។ហើយមកដល់ឆ្នាំ២០១១ លិចទៀត។ លោកបញ្ជាក់ថា: ″ព្រះសហគមន៍នៅកំពង់ធំ អាចប្រឈមមុខនឹងភាពក្រីក្រ បន្ទាប់ពីទឹកជំនន់នេះទៅ។ យើងបារម្ភថា សមាជិកព្រះសហគមន៍ និងប្រជាពលរដ្ឋជាច្រើន គ្រួសារនឹងខ្វះអង្ករហូប″។

លោកធីម ធន់ សមាជិកគណៈកម្មាធិការព្រះសហគមន៍សៀមរាបក្នុងភូមិភាគបាត់ដំបង ក៏មានប្រសាសន៍ថា ព្រះវិហារនៅសៀមរាបភាគច្រើន គឺមិនលិចទេ ដោយសារព្រះវិហារសង់ខ្ពស់។ ប៉ុន្តែដីស្រែជាច្រើនត្រូវបានជនលិចហើយប្រឈមមុខនឹងការខូចខាត។ផ្ទះរបស់សមាជិកព្រះសហគមន៍ និងប្រជាពលរដ្ឋ ជាច្រើនគ្រួសារ ត្រូវទទួលជន់លិច។ លោកបានថា ដីស្រែជាច្រើនហិចតាត្រូវរងនូវផលប៉ះពាល់ ហើយប្រឈមមុខនឹងការខូចខាត បើទឹកជំនន់មិនស្រកនៅក្នុងរយៈពេល ២០ថ្ងៃទៀតទេ។ លោកបន្តថា នៅតាអំ ដីស្រែព្រះសហគមន៍ ដែលមាន២១ហិចតា ត្រូវជនលិចផងដែរ។ លោកក៏បានបញ្ជាក់ថា: ″បើដី ២១ហិចតានេះ ខូចខាត កម្មវិធីចែកបបរក្មេងៗ ដែលមាន នៅក្នុងព្រះសហគមន៍នៅតាអំនេះ ក៏អាចនឹងជួបការលំបាកដែរ″។

លោកអ៊ីវ៉ាន កំប៉ាញ៉ា បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍នៅក្រចេះនៅភូមិភាគកំពង់ចាម ក៏មានប្រសាសន៍ថា ព្រះវិហារត្រូវជនលិច ១,២ម តែអត់មានសមាជិកព្រះសហគមន៍បាត់បង់ជីវិត។

លោកឡាយ ប៉ូល បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍អ្នកលឿង ខេត្តព្រៃវែង ក្នុងភូមិភាគកំពង់ចាម មានប្រសាសន៍ថា ទឹកជំនន់ជន់លិចផ្ទះប្រជាពលរដ្ឋ ជាច្រើនស្រុក នៅក្នុងខេត្តព្រៃវែង។ តែព្រះវិហារមិនបានលិចទេ។ លោកបានថា គេនៅមិនទាន់មានតួលេខអំពីការខូចខាតដោយសារទឹកជំនន់នៅឡើយទេ មកដល់ពេលនេះ។

នៅថ្ងៃទី០១ ខែតុលា ប្រមុខរដ្ឋាភិបាលកម្ពុជា បានឱ្យដឹងថា គិតមកដល់ថ្ងៃទី៣០ កញ្ញានេះ ទឹកជំនន់នៅប្រទេសកម្ពុជា គឺបានសម្លាប់ជីវិតមនុស្សចំនួន ១៤៨នាក់ ហើយមានប្រជាពលរដ្ឋរងផលប៉ះពាល់ចំនួន១៧០.០០០គ្រួសារ និងប៉ះពាល់ដល់ផ្ទៃដីបង្កបង្កើនផលរហូតដល់ ២៧ម៉ឺនហិចតា ហើយអាចនឹងខូចខាតស្រូវរហូតដល់ទៅ ៨ម៉ឺនហិចតា។ តាមតួលេខដែលប្រកាសផ្លូវជាតិ និងផ្លូវខេត្ត ជាង ១០០គ.ម។ ផ្លូវលំចំនួន ១៨០០គ.ម. ស្ពានចំនួន ១៣៦ និងទំនប់មួយចំនួន ត្រូវរងនូវការខូចខាត។ ហើយវត្តចំនួន ៣៦១ សាលារៀន ជាង ៨០០ និងមណ្ឌលសុខភាព៧៥កន្លែង ក៏ត្រូវជនលិចផងដែរ។

មកដល់ថ្ងៃទី០៤ តួលេខថ្មីរបស់គណៈកម្មាធិ-ការគ្រប់គ្រងគ្រោះមហន្តរាយ បានឱ្យដឹងថាពល-រដ្ឋបាត់បង់ជីវិត បានឡើងដល់ ២០៧នាក់ ប៉ះពាល់ដល់ប្រជាពលរដ្ឋ ២១៥៦៦២គ្រួសារ និងដីស្រែចំនួន ២៩១ ០០០ ហិចតាត្រូវរងនូវផលប៉ះពាល់។



Photo : S. Philong

# បងស្រីឡឺវីស អារ៉ែន ចូលរួមអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា

**អ៊ឹម សុខន**

បងស្រីឡឺវីស អារ៉ែន ជាអ្នកទទួលខុសត្រូវថ្នាក់ជាតិនៃក្រុមគ្រួសារម៉ារីណុល មានប្រសាសន៍ថា : "ជាមួយនិងការងារ ដែលខ្ញុំកំពុងបំពេញនេះ គឺព្រះជាម្ចាស់ទ្រង់ បានចាត់ឱ្យយើងមកបំពេញ ក្នុងព្រះនាមរបស់ព្រះអង្គ។ ដោយក្នុងនោះ ព្រះអង្គក៏ចាត់ឱ្យយើងធ្វើទៅតាមអំណោយទាន ដែលទ្រង់បានរៀបចំសម្រាប់យើង"។

សព្វថ្ងៃនេះបងស្រី ឡឺវីស អារ៉ែន ក៏ជាទីប្រឹក្សាសម្រាប់ប្រព័ន្ធអប់រំប្រចាំឯសកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅក្រុងភ្នំពេញផងដែរ។

បងស្រីឡឺវីស អារ៉ែន ប្រសូតនៅក្នុងឆ្នាំ១៩៣៨ នៅមីសីកូ នៃសហរដ្ឋអាមេរិក។ បងស្រីមានបងប្អូនចំនួន ៤នាក់ ដែលមានឪពុកជាធ្វើការបម្រើការងារនៅជួររដ្ឋាភិបាល ហើយម្តាយគឺជាស្ត្រីមេផ្ទះ។ បងស្រីបានមកប្រទេសកម្ពុជា តាំងតែពីឆ្នាំ១៩៩១ ដោយក្នុងនោះ បងស្រីគឺមកក្នុងនាមជាបងស្រីនៃក្រុមគ្រួសារម៉ារីណុល និងធ្វើការងារពាក់ព័ន្ធ ទៅនឹងវិស័យអប់រំក្នុងជួររដ្ឋាភិបាល។

នៅក្នុងសេចក្តីនេះ បងស្រីមានជំនឿថា ព្រះជាម្ចាស់ទ្រង់មានផែនការដ៏ប្រពៃសម្រាប់ប្រទេសកម្ពុជា ដែលកំពុងយកវិស័យអប់រំជាចម្បងក្នុងការបណ្តុះបណ្តាលនូវធនធានមនុស្ស។

បងស្រីបញ្ជាក់ថា: "សម្រាប់ការងារដែលយើងធ្វើ គឺត្រូវជួយគេឱ្យកាន់តែមានភាពប្រសើរឡើងក្នុងការសិក្សា។ ការបង្កើនគុណភាពនៃការអប់រំ គឺមិនមានន័យថា យើងខិតខំដើម្បីទទួលបរិមាណកូនសិស្សឱ្យកាន់តែច្រើននោះឡើយ"។ ស្ថិតនៅលើទីតាំងនៃការងារ បងស្រីអារ៉ែន រៀបរាប់ឱ្យដឹងថា : "ព្រះជាម្ចាស់ចង់ឱ្យយើងស្គាល់ពីសេចក្តីពិតនៅក្នុងការរស់នៅរបស់យើង គឺការលះបង់បម្រើអ្នកដទៃឱ្យ មានន័យថា ដូចជាបម្រើអ្នកដែលខ្លួនស្រលាញ់ និងខ្លួនរបស់យើងផ្ទាល់"។

យ៉ាងណាមិញ បងស្រីប្រាប់ថា ទោះជាបងស្រីធ្លាប់មានបទពិសោធន៍ និងការក្នុងវិស័យអប់រំនេះជាង ១១ឆ្នាំនៅប្រទេសហ្វីលីពីន មុនមកកម្ពុជាក៏ដោយ ក៏បងស្រីនៅតែជួបនូវមានបញ្ហាចោទឡើងសម្រាប់ការងារខាងអប់រំនេះ។

ចំពោះការងារបច្ចុប្បន្ន ដែលរូបបងស្រីធ្វើ មិនថា នៅសកលវិទ្យាល័យ ឬក្នុងគ្រួសារ ទោះបីបងស្រីជួបប្រទះនូវបញ្ហាជាច្រើនយ៉ាងណាក្តី ក៏បងស្រីបញ្ជាក់ថា អ្វីៗតែងមាននូវដំណោះស្រាយនិងទាមទារភាពអត់ធ្មត់ក្នុងការជម្នះ ហើយកិច្ចការអស់ទាំងនេះ គឺត្រូវពឹងផ្អែកលើការទូលអង្វរ ទៅព្រះជាម្ចាស់ និងការជជែករកគំនិតយោបល់ពីក្រុម។



Photo : Rithy

## យុវជនសិង្ហបុរីនឹងមកដកស្រង់បទពិសោធន៍ជាមួយយុវជនព្រះសហគមន៍កំពត

"យុវជនជនជាតិសិង្ហបុរី ប្រមាណ ២០នាក់នឹងមកបំពេញទស្សនកិច្ចដើម្បីធ្វើការដកស្រង់ និងចែករំលែកបទពិសោធន៍ក្នុងការរស់នៅជាមួយនិងយុវជននៅក្នុងព្រះសហគមន៍កំពត"។ នេះបើតាមប្រសាសន៍របស់លោកអ៊ុន សុន បូជាចារ្យ ទទួលខុសត្រូវព្រះសហគមន៍នៅក្នុងខេត្តនោះ។

លោកបូជាចារ្យអ៊ុន សុន បញ្ជាក់ថា : "ពួកគេនឹងមកដល់ព្រះសហគមន៍កំពតនៅថ្ងៃទី១៤ ខែវិច្ឆិកា ហើយចំណាយពេលស្នាក់នៅ និងចែករំលែកបទពិសោធន៍ជាមួយសមាជិកយុវជនយើងនៅក្នុងព្រះសហគមន៍ចំនួន ៤ថ្ងៃ"។

លោកបូជាចារ្យអ៊ុន សុន មានប្រសាសន៍បន្តទៀតថា ពួកគេមកពីសាលាកាតូលិកនៅប្រទេសសិង្ហបុរី ហើយដំណើរមកកម្ពុជាលើកនេះគឺចង់ស្វែងយល់អំពីជីវភាពរស់នៅរបស់យុវជននៅក្នុងព្រះសហគមន៍កាតូលិកកំពត។

បើតាមប្រសាសន៍របស់លោកបូជាចារ្យអ៊ុន សុន នេះគឺជាពេលវេលាមួយដ៏ប្រសើរ មិនត្រឹមតែសម្រាប់យុវជនសិង្ហបុរីប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់យុវជនខ្មែរនៅព្រះសហគមន៍កំពតដែរ ដែលមានឱកាសប្រាស្រ័យទាក់ទងគ្នា និងស្គាល់អំពីស្ថានភាពគ្នាទៅវិញទៅមកដូចជាជីវភាពរស់នៅ និងសុខភាពជាដើម។

លោកអ៊ុន សុន បានឱ្យដឹងទៀតថា មកដល់ពេលនេះ កិច្ចការដែលព្រះសហគមន៍កំពតបានធ្វើជាមួយយុវជនមានច្រើន ដោយរួមមានកម្មវិធីអប់រំភាសាអង់គ្លេស ដែលមានសិស្សជាក្មេងៗ និងយុវជនប្រមាណជាពី៦០ ទៅ ៧០នាក់។ លោកបានបញ្ជាក់ថា : "នេះគឺជាពេលវេលាដែលពួកគេអាចបានជួបភ្ញៀវ និងប្រើប្រាស់ជំនាញភាសាអង់គ្លេស"។

លោកបូជាចារ្យអ៊ុន សុន បន្ថែមថា គោលបំណងរបស់ព្រះសហគមន៍ គឺយើងចង់បង្ហាញឱ្យយុវជនស្គាល់អំពីរបៀបរស់នៅក្នុងសង្គម និងតម្លៃជីវិត។

**ខាន់ ភីរម្យ**

# កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ

ជាត សំភី




Photos : DR

សេដ្ឋកិច្ចពិភពលោកកំពុងជួបនូវវិបត្តិ។ គ្រោះមហន្តរាយធម្មជាតិផ្សេងៗ កំពុងតែគំរាមកំហែងតំបន់ជាច្រើននៅលើពិភពលោកដោយរាប់បញ្ចូលទាំងតំបន់ផលិតស្បៀងផងដែរ។ ទាំងនេះជាមូលហេតុដែលធ្វើប្រជាជនពិភពលោកជួបបញ្ហាកង្វះស្បៀង ដោយសារទិន្នផលកសិកម្ម ធ្លាក់ចុះ ឬខូចខាត និងតម្លៃស្បៀងបានកើនឡើង។

កម្មវិធីស្បៀងអាហារពិភពលោក ឬជាភាសាអង់គ្លេស **WFP (World Food Programme)** គឺជាអង្គភាពជំនួយស្បៀងអាហាររបស់អង្គការសហប្រជាជាតិ។ ស្ថាប័ននេះគឺជាអង្គការមនុស្សធម៌ដ៏ធំបំផុតមួយនៅលើពិភពលោក។ អង្គការស្បៀងអាហារពិភពលោក ផ្តល់ជាជំនួយជាអាហារ ដើម្បីសម្រាលការឈឺចាប់របស់ប្រជាជនដែលទទួលរងគ្រោះទុរភិក្សដោយមហន្តរាយផ្សេងៗ។

ជាមធ្យមជារៀងរាល់ឆ្នាំ កម្មវិធីស្បៀងអហារពិភពលោកផ្តល់ជំនួយចំណីអាហារដល់មនុស្ស ៩០ លាននាក់ ក្នុងនោះ គឺមានកុមារ ៥៨លាននាក់ នៅក្នុងប្រទេសចំនួន ៨០ នៅលើពិភពលោក។

មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានសម្រេចនៅឆ្នាំ១៩៦៣ បង្កើតជាស្ថាប័ននៃកម្មវិធីស្បៀងអាហារពិភពលោកនេះដើម្បីមកជំនួយដល់ប្រជាជនដែលរងគ្រោះ ដោយការអត់ឃ្លានបំផុតនៅលើពិភពលោក។ គោលដៅសំខាន់របស់អង្គការនេះ គឺនាំមកនូវជំនួយបន្ទាន់ សម្រាប់ប្រជាជនរងគ្រោះដោយគ្រោះទុរភិក្ស។ ប៉ុន្តែជំនួយអភិវឌ្ឍក៏ជាផ្នែកនៃសកម្មភាពរបស់អង្គការផងដែរ។

បេសកកម្មរបស់កម្មវិធីស្បៀងអាហារពិភពលោក គឺលុបបំបាត់គ្រោះអត់ឃ្លាន និងភាពក្រីក្រនៅក្នុងពិភពលោក ដោយឆ្លើយតបនូវតម្រូវការបន្ទាន់ និងដោយជំនួយកិច្ចអភិវឌ្ឍន៏សេដ្ឋកិច្ច និងសង្គម។ កម្មវិធីស្បៀងអាហារពិភពលោក សំដៅផងដែរក្នុងការកាត់បន្ថយអត្រាមរណៈរបស់កុមារ និងធ្វើឱ្យប្រសើរឡើងនូវសុខភាពរបស់ស្ត្រីមានគភ៌ដោយការប្រយុទ្ធនឹងកង្វះខាតចំណីអាហារ និងប្រឆាំងនឹងជំងឺ ដូចជា ជំងឺអេដស៏ជាដើម។

តាំងពីឆ្នាំ១៩៩៦ កម្មវិធីស្បៀងអាហារពិភពលោកត្រូវបានដឹកនាំដោយក្រុមប្រឹក្សារដ្ឋបាលដែលបង្កើតឡើង ដោយរដ្ឋ៣៦ ជាសមាជិក។ នៅឆ្នាំ២០០៧ លោកស្រីចូសេត ស៊ីរ៉ង់ ជនជាតិអាម៉េរិក ត្រូវបានតែងតាំងជានាយិកាប្រតិបត្តិ សម្រាប់កម្មវិធីស្បៀងអាហារនៅអង្គការសហប្រជាជាតិ។ លោកស្រីកាន់មុខតំណែងនេះ សម្រាប់អាណត្តិមួយ ដែលមានរយៈពេលប្រាំឆ្នាំ។

មានសកម្មភាពមួយចំនួនរបស់កម្មវិធីស្បៀងអាហារពិភពលោក។ អង្គការស្បៀងអាហារពិភពលោកជួយជនរងគ្រោះដោយមហន្តរាយធម្មជាតិដូចជាការរញ្ជួយដីនៅក្នុងប្រទេសប៉ាគីស្ថាន នៅឆ្នាំ២០០៥។ អង្គការនេះក៏ជួយដល់ជនភៀសខ្លួន និងផ្លាស់ទីលំនៅក្នុងប្រទេសផ្ទាល់របស់ពួកគេ ដោយបង្ខំ ឬតម្រូវឱ្យបោះបង់ចោលដោយជម្លោះ គ្រោះធម្មជាតិផ្សេងៗ ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត និងមហន្តរាយផ្សេងៗទៀតដូចជាអ្វីបានកើតឡើងនៅប្រទេសហៃទី ស៊ូដង់ និងប្រទេសសេរ៉ាលីអូន។

ទ្វីបអាហ្វ្រិក គឺជាតំបន់មួយដែលកម្មវិធីស្បៀងអាហារពិភពលោក តែងតែមានវត្តមានជាទៀងទាត់។ ជំនួយចំណីអាហារទៅកាន់ប្រទេសស៊ូដង់គឺជាកម្មវិធីដ៏សំខាន់បំផុត របស់ភ្នាក់ងារអង្គការនេះដែលជួយឱ្យរស់រានមានជីវិតសម្រាប់ប្រជាជនស៊ូដង់ ៦,៤លាននាក់ នៅឆ្នាំ២០០៦។ នៅឆ្នាំ២០០៧ កម្មវិធីស្បៀងអាហារពិភពលោក ត្រូវការ ៦៨៥ លានដុល្លារដើម្បីជួយប្រជាជនស៊ូដង់៥,៥លាននាក់ ក្នុងនោះ ២,៨លាននាក់ រស់នៅតំបន់ដាហ្វួ។

បន្ទាប់ពីស៊ូដង់ប្រត្តិបត្តិការធំៗ បំផុតរបស់កម្មវិធីស្បៀងអាហារពិភពលោក មានធ្វើនៅប្រទេសអេត្យូពី និងកេនយ៉ា នៅទ្វីបអាហ្វ្រិកផងដែរ។

## ស្ថាបនកម្មវិធីស្បៀងអាហារពិភពលោក

អង្គការស្បៀងអាហារពិភពលោក មានអាសនៈរបស់ខ្លួននៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី។ អង្គការនេះមានបុគ្គលិក ១០៥៨៧ នាក់ នៅឆ្នាំ២០០៦ ក្នុងនោះ ៩២ភាគរយ ធ្វើការងារផ្ទាល់នៅប្រទេសជាមូលដ្ឋាន។

WFP Nations Unies Programme Alimentaire Mondial PAM

រដ្ឋពីរដែលចូលរួមខ្លាំងបំផុត ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លាន គឺមានសហរដ្ឋអាម៉េរិក និងចក្រភពអង់គ្លេស។

ជំនួយអាម៉េរិកបានឡើងដល់ ៤៥០០លានដុល្លារនៅឆ្នាំ២០០៥។ ជំនួយអង់គ្លេសមាន ៨៣៥លានដុល្លារនៅឆ្នាំ២០០៦។ ជំនួយអាឡឺម៉ង់ មានប្រហែល ៣៤០លានដុល្លារ នៅឆ្នាំ២០០៥ និង៣៨២លានដុល្លារនៅឆ្នាំ២០០៦។ ជំនួយបារាំងមានជាមួយនិងទឹកប្រាក់ ៦៧លានដុល្លារនៅឆ្នាំ២០០៥ និង៨២លានដុល្លារនៅឆ្នាំ២០០៦ ព្រមទាំងជំនួយសមាជិកផ្សេងៗទៀត។



Photo : V. Sambath

# តើបុណ្យភ្ជុំនៅក្នុងព្រះសហគមន៍កាតូលិកមានអត្ថន័យយ៉ាងណា?

**ជាត សំភី**

គ្រីស្តបរិស័ទបានយកឱកាសថ្ងៃបុណ្យភ្ជុំដើម្បីទឹករលឹកដល់សន្តបុគ្គល និងមរណបុគ្គលទាំងឡាយ និងបងប្អូនដែលរស់នៅ។ ប៉ុន្តែនៅរងទុក្ខវេទនាផងដែរ។

លោកដួង សាវង្ស អ្នកទទួលខុសត្រូវ-មណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា មានប្រសាសន៍ឱ្យដឹងថា ថ្ងៃបុណ្យភ្ជុំ លោកបូជាចារ្យ និងបងប្អូនគ្រីស្តបរិស័ទ គឺតែងតែជួបជុំគ្នាដើម្បីធ្វើពិធីអភិបូជានៅតាមព្រះវិហារនានា។ លោកដួង សាវង្សក៏បន្តថា នៅក្នុងពិធីអភិបូជា ទីមួយ គឺយើងអរព្រះគុណដល់ព្រះជាម្ចាស់ដែលប្រទានឱ្យយើងមានសន្តបុគ្គល ដែលជាអ្នករស់នៅល្អ និងជាអ្នករស់នៅបង្ហាញវត្តមានព្រះជាម្ចាស់ដោយស្រឡាញ់អ្នកដទៃ។ ទីពីរយើងនឹកដល់មរណបុគ្គល គឺអស់អ្នក ដែលបានស្លាប់ទៅ រួមមានទាំងឪពុកម្តាយ និងបងប្អូនញាតិមិត្តរបស់យើង ទោះបីជាពួកគាត់ជាគ្រីស្តបរិស័ទក្តី ឬក៏មិនមែនគ្រីស្តបរិស័ទក្តី។ យើងអធិដ្ឋានអង្វរព្រះជាម្ចាស់ឱ្យព្រះអង្គទទួលវិញ្ញាណក្ខន្ធរបស់ពួកគាត់ ឱ្យបានចូលក្នុងព្រះរាជ្យរបស់ព្រះអង្គផង។

លោកដួង សាវង្ស បញ្ជាក់ទៀតថា នៅថ្ងៃភ្ជុំនេះដែរ យើងមិនគ្រាន់តែនឹកដល់សន្តបុគ្គល និងមរណបុគ្គលទេ ប៉ុន្តែយើងក៏ធ្វើសេចក្តីប្រកាសនឹកដល់បងប្អូនយើងដែលកំពុងរស់នៅសព្វថ្ងៃ តែរងនូវទុក្ខលំបាក។ ដូច្នេះនៅថ្ងៃអភិបូជា គេមានដាក់នូវប្រាក់ដង្វាយពិសេស ដើម្បីជួយដល់ជនក្រីក្រ។

នៅថ្ងៃបុណ្យភ្ជុំ គ្រីស្តបរិស័ទយកជាម្ហូបអាហារទៅព្រះវិហារ។ បន្ទាប់ពីចប់អភិ-បូជា លោកអភិបាល ឬបូជាចារ្យដែលគាត់ចូលរួម ប្រទានពរលើអាហាររួចទាំងអស់គ្នាហូបអាហាររួមគ្នា។ នៅកន្លែងខ្លះបន្ទាប់ពីអភិបូជា ទាំងអស់គ្នាទៅអធិដ្ឋាន ឧទ្ទិសដល់មរណបុគ្គលនៅផ្នូរ ឬចេតិយ។ លោកដួង សាវង្ស បញ្ជាក់ថា : "យើងមានជំនឿសេចក្តីសង្ឃឹម និងរបៀបរិះគិតតែមួយដូចគ្នា។ ប៉ុន្តែរបៀបប្រតិបត្តិ ប្រហែលជាខុសគ្នាតិចៗ ពីកន្លែងនីមួយៗ។

តាមប្រពៃណីរបស់ព្រះសហគមន៍ នៅថ្ងៃទី១ វិច្ឆិកា គេអរព្រះគុណព្រះជាម្ចាស់សម្រាប់សន្តបុគ្គល និងថ្ងៃ២ វិច្ឆិកា ជាថ្ងៃសម្រាប់មរណបុគ្គល។ ប៉ុន្តែនៅកម្ពុជាប្រ-ជាជនខ្មែរ មានបុណ្យភ្ជុំបិណ្ឌ ក្នុងខែកញ្ញា ដែលជាបុណ្យនឹកដល់អ្នកមរណៈដូចគ្នា។ ដូច្នេះព្រះសហគមន៍ បានសូមការអនុញ្ញាតពីសម្តេចប៉ាបចំពោះបុណ្យ ដែលធ្វើនៅខែវិច្ឆិកា លើកមកធ្វើ នៅបុណ្យភ្ជុំបិណ្ឌរបស់ខ្មែរវិញ។ សម្តេចប៉ាបក៏បានអនុញ្ញាត។

## កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ លេខ៥ (២០០៩_២០១០)




ដើម្បីឆ្លើយតបនឹងតម្រូវការនូវឯកសារបន្ថែមសម្រាប់សិស្សានុ-សិស្សមធ្យមនិងឧត្តមសិក្សា ក្រុមបណ្តាញព័ត៌មាន វប្បធម៌ខ្មែរបានផ្សាយឯកសារល្អៗ លើប្រព័ន្ធវិបសាយមួយឈ្មោះថា **Khmerenaissance**។

គេហទំព័រមានកម្រងអត្ថបទជាច្រើន ដែលទាក់ទងនឹងវប្បធម៌ និងចែកជាប្រធានបទដូចជា មុខរបរចិញ្ចឹមជីវិត ជំនឿទំនៀមទម្លាប់ សិល្បៈ អក្សរសាស្ត្រ សម្រង់ភាសា...។ លើសពីនេះ ក្រុមបណ្តាញព័ត៌មានវប្បធម៌ខ្មែរក៏បោះពុម្ពអត្ថបទទាំងនេះ ដោយចេញជាសៀវភៅមួយលេខក្នុងមួយឆ្នាំ។ នៅក្នុងលេខទី៥នេះ អ្នកអាននឹងស្វែងយល់អំពីភាជន៍ផ្សេងៗពិធីសុំទឹកភ្លៀង និងការស្រាវជ្រាវនៅស្ថានីយ៍បុរេប្រវត្តិល្អាងស្ពាន(បាត់ដំបង) -ល-។

ស្នាដៃនេះមាននិពន្ធនាយក ដូចជាលោកអាំង ជូលាន-ព្រាម ចាន់ម៉ារ៉ា-ស៊ីយ៉ុន សុភារិទ្ធ និងគង់វីរៈ ហើយនិងត្រូវបាន បោះពុម្ពនៅឆ្នាំ២០០៩។

## ដំណើរផ្សងព្រេងរបស់តាំងតាំង_ផ្កាឈូកខៀវ




ដំណើរផ្សងព្រេងរបស់តាំងតាំង ជាក្រុមសៀវភៅឆាករូបភាពបង្កើតឡើងដោយអ្នកគំនូរជនជាតិប៊ែលហ្ស៊ិក លោកហ្សក រ៉េមី ហៅអែកហ្សេ។ តួអង្គឯកក្នុងក្រុមសៀវភៅនេះ មានឈ្មោះថា តាំងតាំង ជាអ្នកយកព័ត៌មានវ័យក្មេងម្នាក់។ គេមានឆ្កែមីលូជាមិត្ត ស្លាប់រស់របស់គេតាមគេជាប់ជានិច្ច។

ក្រុមសៀវភៅនេះមានទាំងអស់ ២៤ចំណងជើង។

រឿងផ្កាឈូកខៀវ គឺជាសៀវភៅទី៥ ដែលរៀបរាប់ពីដំណើរផ្សងព្រេងរបស់អ្នកក្លាហាន តាំងតាំង ក្នុងការតាមកំចាត់ពួកក្រុមជនអន្ធពាលរហូតមកដល់ទីក្រុងសៀងហៃប្រទេសចិន ហើយនៅទីនោះគេបានជួបក្មេងប្រុសចិនម្នាក់ឈ្មោះចាង ដែលក្រោយមកក្លាយជាមិត្តរបស់គេ។ ទាំងពីរនាក់ឆ្លងកាត់ឧបសគ្គជាច្រើន ទម្រាំអាចរំវែកមុខមាត់ពិតរបស់មេក្រុមជនពន្ធពាលលំដាប់អន្តរជាតិម្នាក់។

រឿងនេះត្រូវបកប្រែ ជាភាសាខ្មែរ ដោយសាស្ត្រចារ្យគ្រីស្តូហ្វ ម៉ាកកេ និងក្រុមនិស្សិតផ្នែកបកប្រែនៅដេប៉ាតឺ-ម៉ង់ភាសាបារាំង នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ហួត សុជាតា**

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



សម្រាប់ខែតុលា ២០១១ រៀបចំដោយលោកដួង សាខឿ អ្នកទទួលខុសត្រូវមណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកកម្ពុជា

### *ថ្ងៃអាទិត្យទី២៨ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី៩ ខែ តុលា ២០១១ (ម៉ាថាយ ២២,១៥-២១)*

ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលរំឭកយើងថា សព្វថ្ងៃ ព្រះបិតាសព្វព្រះហឫទ័យ អញ្ជើញមនុស្សទាំងអស់ឱ្យចូលរួមក្នុងអំណរសប្បាយនៃមហាគ្រួសាររបស់ព្រះអង្គ គឺព្រះសហគមន៍។ ព្រះបិតាមិនប្រកាន់ថា ជាអ្នកបាប អ្នកបុណ្យ ឬអ្នកកាន់សាសនាណាក្តី។ ប៉ុន្តែអស់អ្នកដែលចូលក្នុងមហាគ្រួសាររបស់ព្រះអង្គ មិនអាចធ្វើអ្វីស្រេចតែចិត្ត ឬមិនធ្វើអ្វីសោះនោះទេ គឺជាអ្នកប្រែចិត្តរស់នៅស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ស្រឡាញ់ព្រះអង្គ និងស្រឡាញ់អ្នកឯទៀតៗ ដោយចិត្តស្មោះ មិនរកតែប្រយោជន៍សម្រាប់ខ្លួនឯងទេ។

### *ថ្ងៃអាទិត្យទី២៩ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី១៦ ខែ តុលា ២០១១ (ម៉ាថាយ ២២,១៥-២១)*

តាមពិតសំណួររបស់ពួកផារាស៊ី និងពួកស្តេចហេរ៉ូដ គឺមានបំណងចង់ប្រើសាសនាដើម្បីចាប់កំហុសព្រះយេស៊ូ។ ចម្លើយរបស់ព្រះយេស៊ូ ពិតជាជួយឱ្យព្រះអង្គរួចពីអន្ទាក់របស់ពួកគេមែន តែព្រះបន្ទូលចុងក្រោយ គឺព្រះអង្គជំរុញឱ្យគេយកចិត្តទុកដាក់លើព្រះជាម្ចាស់ដែលមានសារៈសំខាន់ជាងអ្វីទាំងអស់។

សព្វថ្ងៃ គ្រីស្តបរិស័ទត្រូវតែគោរពច្បាប់រដ្ឋដែលជួយឱ្យសង្គមមានរបៀបរៀបរយ រីកចម្រើន និងសុខសាន្ត។ គោរពច្បាប់ គឺជារបៀបម្យ៉ាងក្នុងការគោរពព្រះជាម្ចាស់។ ប៉ុន្តែបើមានច្បាប់រដ្ឋខ្លះផ្ទុយពីវិន័យរបស់ព្រះជាម្ចាស់នោះយើងត្រូវតែគោរពវិន័យព្រះអង្គវិញ។

ឧទាហរណ៍ គ្រីស្តបរិស័ទមិនអាចរំលូតកូនបានទេ ដ្បិតព្រះជា ម្ចាស់បង្រៀនឱ្យគោរពជីវិត។ គ្រីស្តបរិស័ទមិនអាចលេងល្បែងស៊ីសងដែលរដ្ឋអនុញ្ញាតជាផ្លូវការបានទេ ដ្បិតព្រះជាម្ចាស់បង្រៀនឱ្យមានចិត្តស្មោះត្រង់នឹងអ្នកឯទៀតៗ។

### *ថ្ងៃអាទិត្យទី៣០ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី២៣ ខែតុលា ២០១១ (ម៉ាថាយ ២២,៣៤-៤០)*

គណៈផារីស៊ីធ្លាប់កាន់តាមវិន័យចំនួន ៦១៣។ ក្នុងចំណោមវិន័យទាំងនោះ តើមួយណាសំខាន់ជាងគេ ? ព្រះយេស៊ូឈ្វេងយល់អំពីជម្រៅនៃធម៌វិន័យទាំងអស់ ហើយព្រះអង្គមានព្រះបន្ទូលអំពីវិន័យដ៏សំខាន់ទាំងពីរ។ ទីមួយ ស្រឡាញ់ព្រះជាម្ចាស់ គឺមានន័យថា យើងប្រព្រឹត្តគ្រប់កិច្ចការ ដោយនឹកគិតទៅព្រះអង្គជានិច្ច មិនមែនសន្សំបុណ្យកុសលឡើយ។ ទីពីរ ស្រឡាញ់អ្នកដទៃ មានន័យថា ស្រឡាញ់មនុស្សទាំងអស់ មិនប្រកាន់ជាតិសាសន៍ ទោះបីជាខ្មាំងសត្រូវរបស់ខ្លួនក្តី ឬជាអ្នកប្រព្រឹត្តអំពើដ៏អាក្រក់ក្តី ដូចព្រះអង្គបានស្រឡាញ់មនុស្សទាំងអស់រហូតដល់បូជាព្រះជន្ម។ នឹកដល់សេចក្តីនេះ យើងដឹងគ្រប់គ្នាថា ខ្លួនខ្វះសេចក្តីស្រឡាញ់។ ចូរយើងអង្វរសូមឱ្យយើងមានចិត្តស្រឡាញ់ដូចព្រះអង្គ។

### *ថ្ងៃអាទិត្យទី៣១ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី៣០ ខែតុលា ២០១១ (ម៉ាថាយ ២៣,១-១២)*

ថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលមកយើង សូមឱ្យយើងប្រយ័ត្នអំពីពាក្យសម្តីដែលយើងប្រកាស និងអំពីកិច្ច ការដែលយើងប្រព្រឹត្ត។

សូមកុំធ្វើខ្លួន ដូចពួក ផារីស៊ី ដែលគិតតែពីកិត្តិយស ឱ្យគេកោតសរសើរ។ សូមធ្វើគ្រប់កិច្ចការដោយគ្មានលាក់ពុត ធ្វើដោយចិត្តស្រឡាញ់ ដោយតម្រង់ចិត្តឆ្ពោះទៅរកព្រះយេស៊ូ និងព្រះបិតាជានិច្ច។ យើងគ្រីស្តបរិស័ទ បំពេញមុខងារផ្សេងៗគ្នា តែយើងជាព្រះកាយតែមួយក្នុងអង្គព្រះគ្រីស្ត ដែលជាព្រះសិរសារ និងជាព្រះបរមគ្រូតែមួយ របស់យើង។

## យុវវ័យជួយស្ត្រី គឺជួយខ្លួនឯង និងសង្គមជាតិ (ត) *(បទពាក្យប្រាំពីរ)*



និពន្ធដោយ : លោកស្រី ឌុង ណារី
ថ្ងៃទី១៤ កញ្ញា ឆ្នាំ២០១១
រៀបរៀងដោយ : លោក ឡុង សុជល

៦១-ប្អូនយុវជនគន់ប្រមើល នៅពេលដើរហើរដំណើរចរ
គោរពគ្រប់ច្បាប់ថែងបន្ត ទើបហៅសិស្សល្អដ៏គំរូ ។

៦២-ចេះច្បាប់របៀបមានវិន័យ ញាតិមិត្តប្រុសស្រីស្តីគិតគូរ
សិស្សល្អបន្តកេរ្តិ៍ដល់គ្រូ ខិតខំតស៊ូព្រោះវិជ្ជា ។

៦៣-ប្អូនជួយខ្លួនឯងស្វែងគំនិត ស្រាវជ្រាវធាតុពិតកុំរុញរា
ឫសគល់ច្បាប់ក្បួនស្ងួនពុំងា ចេះច្បាប់ការពារប្រជាជាតិ ។

៦៤-ការពារម៉ែឪបងប្អូនខ្មែរ រក្សាមើលថែកុំបីឃ្លាត
លើកស្ទួយស្ត្រីប្រពៃទៀត ទឹកចិត្តមាយាទជាចម្បង ។

៦៥-ស្ត្រីលោកស្តីដូចមាតា តែងប្រោសករុណាពេកកន្លង
ចិត្តធន់អំណត់អត់អោនផង ទោះមានខុសឆ្គងរងខន្តី ។

៦៦-មាតាគ្រប់គ្រងបុត្រកល្យាណ កក់ក្តៅសុខសាន្តគ្មានព្រួយភ័យ
ក្រសោបអោបជាប់ក្នុងហឫទ័យ ថ្នាក់ថ្នមបមបីពេញហត្ថា ។

៦៧-ច្បាប់ជាមាតាមេត្តាធម៌ ឯចរាចរគឺបិតា
គ្រប់គ្រងរំពៃសង្កេតការណ៍ តាមថែរក្សាគ្រប់វេលា ។

៦៨-ផ្តែផ្តាំចាំផងកុំបីភ្លេច នឹកឃើញជានិច្ចម្ចូកការពារ
ដំណើរឆ្ងាយជិតស្ថិតធានា ត្រូវត្រៀមការពារជាងព្យាបាល។

៦៩-ទោចក្រយានយានយន្តក្តី គោរពវិន័យច្បាប់ត្រកាល
អត់អោនឱ្យគ្នាគ្រាតំណាល ដំណើរសម្រាលពេលប៉ះពារ ។

៧០-ត្រូវអនុគ្រោះលោះលូកលែង កុំប្រឹងប្រជែងយកឈ្នះគ្នា
សន្សឹមគង់ដល់ផលល្អជា ជ្រុលកិច្ចការងារតិចតួចក្តី ។

# កម្រងរូបថតព្រះសហគមន៍

**សម្បត្តិ ញៀន និងសុទ្ធាឫទ្ធិ**



ពិធីបុណ្យភ្ជុំរបស់ព្រះសហគមន៍នៅថ្ងៃទី២៧ កញ្ញា នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) ភ្នំពេញ



ពិធីសច្ចាប្រណិធានជំហានទីមួយរបស់បងស្រីសៅនី ចូលក្នុងក្រុមបងស្រីឧបការគុណ នៅថ្ងៃទី០៨ តុលា ២០១១



ពិធីបុណ្យភ្ជុំបិណ្ឌនៅព្រះសហគមន៍ ចំការទៀង។



ប្រជុំព្រះគម្ពីនៅនិវេសនដ្ឋានរបស់លោកអតិបាលគូមិតាគភ្នំពេញ។



លោកអតិបាលចែកអំណោយ ដល់ ប្រជាជននៅភូមិសុខសាន្ត ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ



ក្រុមបងប្រុស ក្រុមបងស្រីមេត្តាករុណា និងលោកបូជាចារ្យព្រះសហគមន៍កោះសំពៅ ចូលរួមចែកអំណោយកាលពីថ្ងៃទី០៦-០៨ តុលាកន្លងទៅ នៅស្រុកព្រះស្តេច ខេត្តព្រៃវែង។



លោកអូលីវីយេ អតិបាល គូមិតាគភ្នំពេញទៅចែក អំណោយជនរងគ្រោះដោយ ទឹកជំនន់ នៅខេត្តកណ្តាល



ប្រជាជនដែលរងគ្រោះ ដោយទឹកជំនន់ទទួល អំណោយដូចជា អង្ករ ថ្នាំពេទ្យ មុន និងមី



សិស្សវិទ្យាល័យសន្តហ្វ្រង់ស្វ័រទៅ បារាំងដើម្បីទស្សនកិច្ចសាលាដៃគូ




## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

Radio Veritas Asia
Crossing Borders, Sharing Christ

**វិទ្យុវ៉េរីតាស់អាស៊ី (RVA)**
**ភាសាខ្មែរផ្សាយរយៈពេល ៣០នាទី រាល់ថ្ងៃតាម រលកធាតុអាកាសខ្លី (sw) :**

~ពេលរសៀល ពីម៉ោង ៥:០០នាទី ដល់ម៉ោង ៥:៣០នាទី ផ្សាយក្នុង រលកធាតុអាកាស ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវ៉េរីតាស់ អាស៊ី (RVA)

លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើន ទាក់ទងនឹងជីវិតរស់នៅប្រចាំថ្ងៃ និងសង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកនៅកម្ពុជា។

# ការងារប្រចាំខែ

- ថ្ងៃទី១០-១៣ ខែតុលា : ប្រជុំបូជាចារ្យវ័យក្មេង ២០នាក់នៅព្រះសហគមន៍កំពង់សោម។
- ថ្ងៃទី១១ ខែតុលា : ក្រុមសិស្សមកពីប្រទេសសិង្ហបុរី ១៥នាក់ ទៅសួរសុខទុក្ខមណ្ឌលខ្វាលថ្មីនៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី១៤ ខែតុលា : ពិធីឡើងផ្ទះថ្មីរបស់ក្រុមបងស្រីជប៉ុន ដោយមានលោកអភិបាលអូលីវីយេជាអធិបតីក្នុងពិធីកាត់ខ្សែបូ ដែលធ្វើឡើងនៅព្រះសហគមន៍កំពត។
- ថ្ងៃទី១៤-១៥ ខែតុលា : បើកវគ្គសិក្សាអប់រំគ្រីស្តបរិស័ទនៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច) រាជធានីភ្នំពេញ។
- ថ្ងៃទី១៨ ខែតុលា : ពិធីសម្ពោធអគារ និងបើកវគ្គសិក្សាថ្មីនៅទេវវិទ្យាល័យ ភ្នំពេញ។
- ថ្ងៃទី២២-២៣ ខែតុលា : សិក្ខាសាលាប្រធាន និងអនុប្រធានយុវជន ដែលមកពីព្រះសហគមន៍កំពត តាកែវ និងកំពង់សោមនៅការិយាល័យយុវជនទីក្រុងភ្នំពេញ។
- ថ្ងៃទី២៤ តុលា ដល់ថ្ងៃទី០៤ វិច្ឆិកា : លោកបូជាចារ្យម៉ានីរ៉ាត មកពីប្រទេសថៃ មកបង្រៀនអំពីច្បាប់របស់ព្រះសហគមន៍នៅទេវវិទ្យាល័យ ទីក្រុងភ្នំពេញ។
- ថ្ងៃទី២៥-២៧ ខែតុលា : ប្រជុំរួមរបស់មណ្ឌលសកម្មភាពបាត់ដំបង នៅសៀមរាប។
- ថ្ងៃទី២៨ ខែតុលា : ប្រជុំសម្រាប់លោកបូជាចារ្យទាំងអស់មកពីមណ្ឌលសកម្មភាពបាត់ដំបង នៅព្រះសហគមន៍សៀមរាប។
- ថ្ងៃទី២៩-៣០ ខែតុលា : បើកវគ្គសិក្សា និងសិក្ខាសាលាសម្រាប់ប្រធាន និងអនុប្រធានយុវជន ដែលមកពីព្រះសហគមន៍ភ្នំពេញ និងព្រះសហគមន៍ចំប៉ា នៅព្រះវិហារព្រះកុមារយេស៊ូ (បឹងទំពុន) ទីក្រុងភ្នំពេញ។


**ការិយាល័យព័ត៌មានកាតូលិក**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120;
E-mail : csccambodia@gmail.com
Website : www.catholiccambodia.org
អ្នកសម្របសម្រួល : លោកស្រ៊ីប្រាម៉ុង វីរជ័យ ។ ប្រធាន : លោកលី សុវណ្ណា ។
Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧